# អាហារូបត្ថម្ភ ៖ ត្រូវបរិភោគអ្វីដើម្បីឲ្យមានសុខភាពល្អ

ជំពូកទី ១១

## ជំងឺដែលបណ្តាលមកពីការបរិភោគមិនត្រឹមត្រូវ



មនុស្សត្រូវការចំណីអាហារល្អដើម្បីឲ្យរាងកាយលូតលាស់បានល្អ អាចធ្វើការងារខ្លាំង បាន និងនៅតែមានសុខភាពល្អ។ មានជំងឺទូទៅជាច្រើន កើតពីការបរិភោគមិនគ្រប់គ្រាន់។

មនុស្សដែលខ្សោយកម្លាំង ឬមានជំងឺ ដោយសារគាត់ពុំបានបរិភោគគ្រប់គ្រាន់ ឬមិនបានបរិភោគអាហារដែលរាងកាយរបស់គាត់ត្រូវការ ត្រូវបានគេហៅថា មានអាហារូបត្ថម្ភមិនគ្រប់គ្រាន់ ឬ**កង្វះអាហារូបត្ថម្ភ**។ គាត់មានជំងឺ ***កង្វះអាហារូបត្ថម្ភ***។

ការមានអាហារូបត្ថម្ភមិនគ្រប់គ្រាន់ អាចបណ្តាលឲ្យមានបញ្ហាសុខភាពមួយចំនួនដូចខាងក្រោម ៖

**ចំពោះកុមារ**

- មិនលូតលាស់ ឬមិនឡើងទម្ងន់តាមធម្មតា (អាន ទំ.២៩៧)
- មានការយឺតយ៉ាវក្នុងការចេះដើរ និយាយ ឬគិត
- មានពោះធំ ដៃនិងជើងតូចៗ
- ជំងឺទូទៅ និងការបង្ករោគដែលមិនងាយជាសះស្បើយ តែងមានសភាពធ្ងន់ធ្ងរ រួចបណ្តាលឲ្យស្លាប់
- ខ្សោយកម្លាំង កុមារមិនសប្បាយចិត្ត និងមិនលេង
- ហើមជើង មុខ និងដៃ ហើយភាគច្រើនមានដំបៅ ឬស្នាមផ្សេងៗនៅលើស្បែក
- សរសៃសក់ស្គរៗ បះៗ ឬជ្រុះសក់ ឬបាត់ពណ៌របស់វា និងមិនភ្លឺថ្លា
- មើលមិនច្បាស់នៅពេលយប់ ភ្នែកស្ងួត ងងឹតភ្នែក

**ចំពោះមនុស្សគ្រប់រូប**

- ខ្សោយ និងអស់កម្លាំង
- មិនឃ្លានអាហារ
- មានភាពស្លេកស្លាំង
- មានដំបៅនៅចង្កេះបបូរមាត់
- ឈឺចាប់ឬមានដំបៅនៅអណ្តាត
- ក្រហាយ ឬស្ពឹកជើង

ទោះបីជាបញ្ហាខាងក្រោមនេះអាចបណ្តាលមកពីមូលហេតុផ្សេងទៀតក៏ដោយ ពេលខ្លះ ការបរិភោគមិនត្រឹមត្រូវក៏ជាមូលហេតុរបស់វា និងជាមូលហេតុដែលតែងតែធ្វើវាមានសភាពកាន់តែធ្ងន់ធ្ងរដែរ ៖

- ជំងឺរាក
- ការបង្ករោគជាញឹកញាប់
- ហ៊ឹងត្រចៀក
- ឈឺក្បាល
- ឈាមអញ្ចាញធ្មេញ ឬអញ្ចាញធ្មេញឡើងក្រហម
- ស្បែកងាយជាំ
- ឈាមច្រមុះ
- មិនស្រួលក្នុងក្រពះ
- ស្បែកស្ងួត និងប្រេះ
- ញ័រទ្រូង
- ថប់អារម្មណ៍ និងមានបញ្ហាផ្លូវចិត្ត
- ជំងឺក្រិនថ្លើម

**ការខ្វះអាហារូបត្ថម្ភក្នុងពេលមានផ្ទៃពោះ** បណ្តាលឲ្យម្តាយខ្សោយកម្លាំង និងមានភាពស្លេកស្លាំង និងបង្កើនការប្រឈមនឹងការស្លាប់បាន ក្នុងពេលឬក្រោយពេលសម្រាលកូន។ វាក៏ជាមូលហេតុនៃការរលូតកូន ឬការស្លាប់នៃទារកក្នុងពេលកើត ទារកតូចពេក ឬទារកមិនគ្រប់លក្ខណៈ។

## ការបរិភោគត្រឹមត្រូវ ជួយឲ្យរាងកាយធន់នឹងជំងឺ។

ការបរិភោគមិនត្រឹមត្រូវអាចជាមូលហេតុផ្ទាល់នៃជំងឺដែលបានរៀបរាប់ដូចខាងលើ។ ប៉ុន្តែអ្វីដែលជាការសំខាន់នោះគឺថា ការខ្វះអាហារូបត្ថម្ភ ធ្វើឲ្យសមត្ថភាពរបស់រាងកាយក្នុងការទប់ទល់នឹងជំងឺគ្រប់ប្រភេទ ចុះខ្សោយ ជាពិសេសគឺការបង្ករោគ ៖

- កុមារដែលមានការខ្វះអាហារូបត្ថម្ភ ទំនងជាងាយកើតជំងឺរាកយ៉ាងធ្ងន់ធ្ងរ នឹងងាយស្លាប់ដោយសារជំងឺនេះជាងកុមារដែលមានអាហារូបត្ថម្ភល្អ។
- ជំងឺកញ្ជ្រឹលមានគ្រោះថ្នាក់យ៉ាងខ្លាំង នៅកន្លែងដែលមានកុមារជាច្រើនខ្វះអាហារូបត្ថម្ភ។
- ជំងឺរបេងកើតឡើងជាញឹកញាប់ និងមានសភាពធ្ងន់ធ្ងរយ៉ាងឆាប់រហ័ស លើកុមារដែលខ្វះអាហារូបត្ថម្ភ។
- ជំងឺក្រិនថ្លើម (ដែលមូលហេតុមួយផ្នែករបស់វាបណ្តាលមកពីការផឹកស្រាច្រើន) កើតឡើងជាញឹកញាប់ និងមានសភាពធ្ងន់ធ្ងរ ចំពោះអ្នកដែលខ្វះអាហារូបត្ថម្ភ។
- សូម្បីតែជំងឺស្រាលៗដូចជាជំងឺផ្តាសាយធម្មតា ក៏តែងតែមានសភាពធ្ងន់ធ្ងរ មិនងាយជាសះស្បើយ ឬនាំឲ្យកើតជំងឺរលាកសួតជាញឹកញាប់ លើអ្នកដែលខ្វះអាហារូបត្ថម្ភ។

## ការបរិភោគត្រឹមត្រូវ ជួយឲ្យអ្នកជំងឺឆាប់ជាសះស្បើយ។

ចំណីអាហារល្អមិនត្រឹមតែជួយបង្ការជំងឺប៉ុណ្ណោះទេ វាថែមទាំងជួយរាងកាយអ្នកជំងឺក្នុងការប្រឆាំងនឹងជំងឺ ព្រមទាំងជួយឲ្យឆាប់ជាសះស្បើយឡើងវិញថែមទៀតផង។ ដូច្នេះនៅពេលដែលមនុស្សម្នាក់មានជំងឺ ការបរិភោគអាហារបំប៉នគ្រប់គ្រាន់ មានសារសំខាន់ណាស់។

ជាអកុសល ម្តាយមួយចំនួនបែរជាឈប់ផ្តល់អាហារឲ្យកុមារ ឬឈប់ផ្តល់អាហារបំប៉នប្រភេទខ្លះ នៅពេលដែលកុមារមានជំងឺឬមានជំងឺរាក ដូច្នេះកុមារនោះកាន់តែខ្សោយទៅៗ មិនអាចប្រឆាំងនឹងជំងឺ ហើយអាចនឹងស្លាប់បាន។ **កុមារដែលមានជំងឺ ត្រូវការចំណីអាហារ! បើកុមារដែលមានជំងឺ មិនចង់បរិភោគអាហារ លើកទឹកចិត្តពួកគេឲ្យបរិភោគ។**

ផ្តល់អាហារដល់កុមារឲ្យបានច្រើនតាមដែលពួកគេអាចបរិភោគនិងផឹកបាន។ ត្រូវមានចិត្តអត់ធ្មត់។ ជាទូទៅ កុមារដែលមានជំងឺតែងតែមិនចង់បរិភោគច្រើនទេ។ ដូច្នេះត្រូវផ្តល់អាហារដល់ពួកគេឲ្យបានច្រើនដងក្នុងពេលថ្ងៃ។ ជាមួយគ្នានេះដែរ ត្រូវប្រាកដថាកុមារផឹកទឹកបានច្រើន និងបានបត់ជើងតូចច្រើនដងក្នុងមួយថ្ងៃ។ បើកុមារមិនបរិភោគអាហាររឹងទេ ត្រូវកិនវា ហើយបញ្ចុកកុមារដូចបបរដែរ។

ជាញឹកញាប់ រោគសញ្ញានៃការខ្វះអាហារូបត្ថម្ភ ច្រើនតែចាប់ផ្តើមបង្ហាញឡើងនៅពេលដែលមនុស្សនោះ មានជំងឺផ្សេងៗទៀត។ ឧទាហរណ៍ កុមារដែលរាកជាច្រើនថ្ងៃមកហើយ អាចមានហើមដៃនិងជើង និងហើមមុខ មានស្នាមខ្មៅៗ ឬមានដំបៅរបកស្បែកនៅលើជើង។ នេះគឺជារោគសញ្ញានៃការខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។ កុមារនេះត្រូវការអាហារល្អៗបន្ថែមទៀត! និងកាន់តែញឹកញាប់ទៀត។ ផ្តល់អាហារដល់កុមារឲ្យបានច្រើនដងក្នុងមួយថ្ងៃៗ។

ក្នុងពេលនិងក្រោយពេលជាសះស្បើយពីជំងឺណាមួយ ការសំខាន់គឺត្រូវបរិភោគឲ្យបានត្រឹមត្រូវ។

ការបរិភោគត្រឹមត្រូវ និងការថែរក្សាអនាម័យ គឺជាការធានាដ៏ប្រសើរបំផុតសម្រាប់សុខភាព។



# ហេតុអ្វីបានជាការបរិភោគត្រឹមត្រូវ មានសារសំខាន់

អ្នកដែលបរិភោគមិនត្រឹមត្រូវ មាន**កង្វះអាហារូបត្ថម្ភ**។ បញ្ហានេះអាចកើតឡើងដោយសារការបរិភោគអាហារមិនគ្រប់គ្រាន់(កង្វះអាហារូបត្ថម្ភទូទៅ) ដោយសារការមិនបានបរិភោគប្រភេទអាហារត្រឹមត្រូវ(កង្វះអាហារូបត្ថម្ភប្រភេទណាមួយ) ឬដោយការបរិភោគអាហារប្រភេទណាមួយច្រើនពេក(ធាត់ពេក មើលទំ.១២៦)។

មនុស្សគ្រប់រូបអាចមានកង្វះអាហារូបត្ថម្ភទូទៅ ប៉ុន្តែវាមានគ្រោះថ្នាក់ខ្លាំង ចំពោះ ៖

- **កុមារ** ពីព្រោះពួកគេត្រូវការអាហារយ៉ាងច្រើនដើម្បីជួយឲ្យមានការលូតលាស់ និងមានសុខភាពល្អ
- **ស្ត្រីក្នុងវ័យមានកូន** ជាពិសេសបើពួកគេមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន ពីព្រោះពួកគេត្រូវការអាហារបន្ថែម ដើម្បីឲ្យមានសុខភាពល្អ ដើម្បីឲ្យមានទារកដែលមានសុខភាពល្អ និងដើម្បីអាចធ្វើការងារប្រចាំថ្ងៃបាន
- **មនុស្សចាស់** ពីព្រោះពួកគាត់ច្រើនតែមិនសូវមានធ្មេញ និងមានការបាត់បង់រសជាតិអាហារ ដូច្នេះពួកគាត់មិនអាចបរិភោគបានច្រើនទេ នៅពេលបរិភោគម្តងៗ ទោះបីជាពួកគាត់នៅតែត្រូវការបរិភោគឲ្យបានត្រឹមត្រូវដើម្បីមានសុខភាពល្អក៏ដោយ។

កុមារដែលខ្វះអាហារូបត្ថម្ភមិនសូវមានការលូតលាស់ល្អទេ។ ជាធម្មតាកុមារមានរាងកាយស្គមស្គាំង និងមានកម្ពស់ទាបជាងកុមារធម្មតាដទៃទៀត។ ម៉្យាងទៀត កុមារនេះដូចឆាប់ខឹង យំច្រើន ព្រមទាំងធ្វើចលនានិងលេងតិចជាងកុមារដទៃទៀត ហើយមានជំងឺជាញឹកញាប់។ បើកុមារនោះមានជំងឺរាក ឬការបង្ករោគផ្សេងៗទៀតផងនោះ ពួកគេនឹងស្រកទម្ងន់យ៉ាងលឿន។ វិធីដ៏ល្អមួយដើម្បីពិនិត្យមើលថាតើកុមារមានការខ្វះអាហារូបត្ថម្ភឬទេ គឺការវាស់ទំហំរង្វង់ដើមដៃរបស់គាត់។

### ការពិនិត្យកុមារ ដើម្បីរកមើលការខ្វះអាហារូបត្ថម្ភ ៖ រោគសញ្ញានៅលើដើមដៃ




បន្ទាប់ពីអាយុមួយឆ្នាំ កុមារដែលមានទំហំរង្វង់ដើមដៃតូចជាង ១៣,៥ស.ម កុមារនោះមានការខ្វះអាហារូបត្ថម្ភ ទោះបីជាជើង ដៃនិងមុខរបស់កុមារ មើលទៅដូចជាធាត់យ៉ាងណាក៏ដោយ។ បើរង្វាស់នេះតូចជាង១២,៥ម.ស នោះមានន័យថា កុមារខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។

វិធីល្អមួយទៀតក្នុងការមើលថាកុមារមានអាហារូបត្ថម្ភល្អឬមិនល្អ គឺការថ្លឹងទម្ងន់របស់គេឲ្យបានទៀងទាត់ ៖ មួយខែម្តងក្នុងឆ្នាំទីមួយ បន្ទាប់មក៣ខែម្តង។ កុមារដែលមានអាហារូបត្ថម្ភគ្រប់គ្រាន់ឡើងទម្ងន់ជាប្រចាំ។ ការថ្លឹងទម្ងន់កុមារ និងការប្រើប្រាស់ប័ណ្ណសុខភាពកុមារ ត្រូវបានពន្យល់លម្អិតនៅជំពូកទី២១។

# ការបង្ការកង្វះអាហារូបត្ថម្ភ

ដើម្បីរក្សាសុខភាពឲ្យបានល្អ រាងកាយរបស់យើងត្រូវការចំណីអាហារល្អយ៉ាងច្រើន។ អាហារដែលយើងបរិភោគត្រូវតែបំពេញតម្រូវការជាច្រើន។ ទីមួយ អាហារនោះគួរតែផ្តល់**ថាមពល**គ្រប់គ្រាន់ ដើម្បីឲ្យរាងកាយស្វាហាប់ និងមាំមួន។ មួយទៀត អាហារនោះត្រូវតែជួយ**ស្ថាបនា ជួសជុល** និង**ការពារ**ផ្នែកផ្សេងៗនៃរាងកាយយើង។ ដើម្បីឲ្យបានដូច្នេះ យើងត្រូវបរិភោគអាហារផ្សំគ្នាជាច្រើនរៀងរាល់ថ្ងៃ។

# អាហារចម្បង និងអាហារជំនួយ

នៅប្រទេសជាច្រើន ប្រជាជនភាគច្រើនបរិភោគអាហារចម្បងតែមួយមុខដែលមានតម្លៃថោក នៅស្ទើរតែគ្រប់ពេលបរិភោគអាហារទាំងអស់។ អាហារនោះមានដូចជា បាយ ពោត ស្រូវមីយេ ស្រូវសាលី ក្លូច ដំឡូង ខ្នុរ ឬផ្លែចេក។ **ជាទូទៅ អាហារចម្បងទាំងនេះ បានបំពេញនូវតម្រូវការអាហារប្រចាំថ្ងៃភាគច្រើនរបស់រាងកាយ។**

ទោះជាយ៉ាងនេះក្តី **អាហារចម្បង**តែមួយមុខមិនគ្រប់គ្រាន់ក្នុងការធ្វើឲ្យមនុស្សម្នាក់មានសុខភាពល្អឡើយ។ មនុស្សត្រូវការ**អាហារជំនួយ**មួយចំនួនទៀត។ នេះជាការពិត ជាពិសេសសម្រាប់កុមារដែលកំពុងលូតលាស់ ស្ត្រីមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន និងមនុស្សចាស់។

សូម្បីតែកុមារដែលបានទទួលអាហារចម្បងគ្រប់គ្រាន់និងទៀងទាត់ក៏ដោយ ក៏គាត់នៅតែអាចមានរូបរាងស្គម និងខ្សោយកម្លាំងដែរ។ នេះដោយសារតែក្នុងអាហារចម្បងនោះមានជាតិទឹកនិងសរសៃឆ្មារៗច្រើនពេក ដែលធ្វើឲ្យពោះរបស់កុមារ ពេញ មុនពេលដែលពួកគេបានទទួលថាមពលគ្រប់គ្រាន់ ដើម្បីជួយឲ្យរាងកាយលូតលាស់។

វិធី២យ៉ាងដែលយើងអាចធ្វើបានដើម្បីជួយបំពេញតម្រូវការថាមពលរបស់កុមារ ៖

១. **ផ្តល់អាហារដល់កុមារឲ្យបានញឹកញាប់** យ៉ាងតិច៥ដងក្នុង១ថ្ងៃ ពេលដែលកុមារនៅតូច ស្គមខ្លាំង ឬមិនសូវមានការលូតលាស់ល្អ។ លើសពីនេះទៀត ឲ្យកុមារបរិភោគចំណីផ្សេងៗទៀត នៅចន្លោះពេលអាហារសំខាន់ៗ។




២. **បន្ថែមអាហារជំនួយដែលមានថាមពលខ្ពស់** ដូចជាប្រេងនិងស្ករ ឬទឹកឃ្មុំ ទៅក្នុងអាហារចម្បង។ ការដែលល្អបំផុត គឺ ត្រូវបន្ថែមប្រេងបន្លែ ឬអាហារដែលមានជាតិប្រេង ដូចជាគ្រាប់រុក្ខជាតិ សណ្តែកដី ឬគ្រាប់ធញ្ញជាតិផ្សេងៗ ជាពិសេសល្ពៅ ឬគ្រាប់ល្ង។




*ដើម្បីបំពេញតម្រូវការថាមពលរបស់គាត់ កុមារនេះ ត្រូវការបរិភោគបាយច្រើនដូចនេះ។*

*ប៉ុន្តែ គាត់នឹងត្រូវការបាយតែប្រហែលនេះទេ ប្រសិនបើមានប្រេងបន្លែខ្លះបន្ថែមទៅក្នុងបាយនោះ។*

ការបន្ថែមអាហារដែលមានថាមពលខ្ពស់ ទៅក្នុងអាហារចម្បង ជួយផ្តល់ថាមពលបន្ថែមទៀត។ ម៉្យាងទៀត មាន**អាហារជំនួយ២ប្រភេទផ្សេងទៀត** ដែលគួរត្រូវបានបន្ថែមទៅក្នុងអាហារចម្បង៖

នៅពេលដែលអាច បន្ថែម**អាហារស្ថាបនារាងកាយ** (ប្រូតេអ៊ីន) ដូចជា សណ្តែក ទឹកដោះគោ ស៊ុត សណ្តែកដី ត្រី និងសាច់។

ព្យាយាមបន្ថែម**អាហារការពាររាងកាយ**ផងដែរ ដូចជា ផ្លែក្រូច ឬផ្លែឈើពណ៌លឿង បន្លែ និងបន្លែពណ៌បៃតងចាស់។ អាហារការពាររាងកាយផ្តល់វីតាមីន និងជាតិរ៉ែយ៉ាងសំខាន់ (មើលទំ.១១៣)។

## ការបរិភោគត្រឹមត្រូវដើម្បីឲ្យមានសុខភាពល្អជានិច្ច

ជាធម្មតា អាហារចម្បងដែលគ្រួសាររបស់អ្នកបរិភោគ ផ្តល់នូវថាមពលនិងអាហារូបត្ថម្ភ**ភាគច្រើន** ដែលរាងកាយត្រូវការ **ប៉ុន្តែមិនគ្រប់គ្រាន់**ទេ។ ដោយបន្ថែម**អាហារជំនួយ**ទៅក្នុង**អាហារចម្បង** អ្នកអាចទទួលបានអាហារបំប៉នដែលមានតម្លៃថោក។ អ្នកមិនចាំបាច់បរិភោគអាហារទាំងអស់ដែលបានរៀបរាប់ខាងក្រោមនេះ ដើម្បីឲ្យមានសុខភាពល្អទេ។ **បរិភោគអាហារចម្បងដែលអ្នកធ្លាប់បរិភោគ ហើយបន្ថែមអាហារជំនួយដែលអាចរកបានក្នុងតំបន់របស់អ្នក។** ព្យាយាមបញ្ចូលអាហារជំនួយ ពីក្រុមនីមួយៗ តាមដែលអាចធ្វើទៅបាន។

អាហារជំនួយថាមពល

*ឧទាហរណ៍ ៖*



**ខ្លាញ់** (ប្រេងបន្លែ ប័រ ខ្លាញ់ជ្រូក)

**អាហារដែលសំបូរជាតិខ្លាញ់** (ដូង សាច់លាយខ្លាញ់)

**គ្រាប់ធញ្ញជាតិ** (សណ្តែកដី គ្រាប់ស្វាយចន្ទី)

**គ្រាប់ប្រេងរុក្ខជាតិ** (ល្ពៅ ឪឡឹក ល្ង គ្រាប់ផ្កាឈូករត្ន័)

**ជាតិស្ករ** (ស្ករ ទឹកឃ្មុំ ទឹកអំពៅ ស្ករអំពៅ និងស្ករត្នោត)។

*ចំណាំ ៖* គ្រាប់ធញ្ញជាតិនិងប្រេងរុក្ខជាតិក៏មានគុណសម្បត្តិជាអាហារស្ថាបនារាងកាយដែរ។

*ចងចាំថា ៖* ការផ្តល់អាហារដល់កុមារឲ្យបាន **គ្រប់គ្រាន់** និង**ញឹកញាប់** (៣ទៅ៥ដងក្នុង១ថ្ងៃ)មានប្រយោជន៍ជាងប្រភេទអាហារដែលអ្នកផ្តល់ឲ្យកុមារទៅទៀត។

### អាហារចម្បង






ឧទាហរណ៍ ៖

**គ្រាប់ធញ្ញជាតិ** (ស្រូវសាលី ពោត អង្ករ)

**ម្សៅមើម** (ក្តួច ដំឡូង ត្រាវ)

**ម្សៅផ្លែឈើ** (ចេក ខ្នុរ plantain)

ចំណាំ ៖ អាហារចម្បងជាប្រភពថាមពលដែលមានតម្លៃថោក។ គ្រាប់ធញ្ញជាតិក៏ផ្តល់ប្រូតេអ៊ីនដែក និងវីតាមីនមួយចំនួន ក្នុងតម្លៃថោកដែរ។

**អាហារលូតលាស់**

(ប្រូតេអ៊ីន ឬអាហារជំនួយស្ថាបនារាងកាយ)



ឧទាហរណ៍ ៖

**បន្លែ** (សណ្តែក សណ្តែកបារាំង)

**គ្រាប់រុក្ខជាតិ** (សណ្តែកដី គ្រាប់ស្វាយចន្ទី)

**ផលិតផលសត្វ** (ទឹកដោះគោ ស៊ុត ទឹកដោះជូរ ត្រី សាច់មាន់ សាច់សត្វល្អិត)

**អាហារស្រស់ថ្លា**



(វីតាមីន និងសារធាតុរ៉ែ ឬអាហារការពារ)

ឧទាហរណ៍ ៖

**បន្លែ** (បន្លែពណ៌បៃតង ប៉េងប៉ោះ ការ៉ុត ល្ពៅ ដំឡូង និងម្ទេសផ្លោក)

**ផ្លែឈើ** (ផ្លែស្វាយ ផ្លែក្រូច ផ្លែល្ហុង។ល។)

កំណត់សំគាល់ចំពោះបុគ្គលិកផ្នែកអាហារូបត្ថម្ភ៖ ផែនការសម្រាប់បំពេញតម្រូវការអាហារនេះ ដូចគ្នានឹងការបង្រៀនអំពីក្រុមអាហារដែរ ប៉ុន្តែផ្តោតសំខាន់ទៅលើការផ្តល់អាហារចម្បងតាមទំនៀមទម្លាប់ឲ្យបានគ្រប់គ្រាន់ ហើយសំខាន់បំផុតគឺ **ផ្តល់អាហារជំនួយដែលសំបូរថាមពលឲ្យបានគ្រប់គ្រាន់និងញឹកញាប់។** វិធីសាស្ត្រនេះអាចប្រែប្រួលទៅតាមធនធាននិងកម្រិតលទ្ធភាពរបស់គ្រួសារក្រីក្រ។

# របៀបសំគាល់ការខ្វះអាហារូបត្ថម្ភ

ក្នុងចំណោមប្រជាជនក្រីក្រ **ការខ្វះអាហារូបត្ថម្ភតែងតែមានសភាពធ្ងន់ធ្ងរចំពោះកុមារ ដែលត្រូវការអាហារបំប៉នជាច្រើនដើម្បីលូតលាស់និងមានសុខភាពល្អ។** កង្វះអាហារូបត្ថម្ភមានទម្រង់ផ្សេងៗគ្នា ៖

## កង្វះអាហារូបត្ថម្ភកម្រិតស្រាល



នេះគឺជាទម្រង់ដែលមានញឹកញាប់ជាងគេ ប៉ុន្តែមិនប្រាកដថាដូច្នេះរហូតទេ។ កុមារមិនលូតលាស់ ឬមិនឡើងទម្ងន់បានលឿនដូចកុមារដែលមានអាហារូបត្ថម្ភល្អទេ។ ទោះបីជាកុមារនោះអាចមានរាងកាយ តូចឬស្គមបន្តិចក៏ដោយ ក៏កុមារនោះមើលទៅមិនដូចជាមានជំងឺទេ។ ប៉ុន្តែដោយសារតែកុមារមាន អាហារូបត្ថម្ភមិនគ្រប់គ្រាន់ គេអាចមិនសូវមានកម្លាំង(ធន់)ប្រឆាំងនឹងការបង្ករោគផ្សេងៗឡើយ។ ដូច្នេះ កុមារនេះអាច**ក្លាយទៅជាមានជំងឺធ្ងន់ធ្ងរ** ហើយមិនឆាប់ជាសះស្បើយដូចកុមារដែលមានអាហារូបត្ថម្ភល្អ។

កុមារដែលមានការខ្វះអាហារូបត្ថម្ភក្នុងទម្រង់មួយនេះ អាចកើតជំងឺរាកនិងផ្តាសាយជាញឹកញាប់។ ជំងឺផ្តាសាយរបស់កុមារទាំងនេះបន្លាយពេលយូរ ហើយងាយនឹងបណ្តាលទៅជាជំងឺរលាកសួត។ ជំងឺកញ្ជ្រឹល របេង និង **ជំងឺឆ្លងជាច្រើនទៀត មានគ្រោះថ្នាក់យ៉ាងខ្លាំង** ចំពោះកុមារដែលខ្វះអាហារូបត្ថម្ភទាំងនេះ។ ភាគច្រើន កុមារទាំងនេះស្លាប់។

ការដែលសំខាន់គឺត្រូវថែទាំកុមារទាំងនេះដោយប្រុងប្រយ័ត្ន ហើយត្រូវផ្តល់អាហារឲ្យបានគ្រប់គ្រាន់ ***មុនពេល*** ពួកគេធ្លាក់ខ្លួនឈឺធ្ងន់។ ហេតុនេះហើយបានជាការថ្លឹងទម្ងន់ ឬការវាស់ទំហំរង្វង់ដើមដៃកុមារតូចៗយ៉ាងទៀតទាត់ គឺជាការសំខាន់បំផុត។ វាជួយឲ្យយើងអាចសំគាល់និងកែលម្អកង្វះអាហារូបត្ថម្ភកម្រិតស្រាលនេះបានទាន់ពេល។

**សូមធ្វើតាមពិធីសារសម្រាប់ការបង្ការកង្វះអាហារូបត្ថម្ភ**

## កង្វះអាហារូបត្ថម្ភកម្រិតធ្ងន់

វាកើតឡើងជាញឹកញាប់បំផុតលើទារកដែលឆាប់ផ្តាច់ដោះ ឬផ្តាច់ដោះភ្លាមៗ ព្រមទាំងលើកុមារដែលមិនបានទទួលអាហារថាមពលញឹកញាប់គ្រប់គ្រាន់។ កង្វះអាហារូបត្ថម្ភកម្រិតធ្ងន់ច្រើនចាប់ផ្តើមកើតមាននៅពេលកុមារមានជំងឺរាក ឬការបង្ករោគអ្វីមួយ។ ជាធម្មតា យើងអាចសំគាល់កុមារដែលខ្វះអាហារូបត្ថម្ភកម្រិតធ្ងន់ បានដោយមិនចាំបាច់ធ្វើការវាស់អ្វីមួយទេ។ ឧទាហរណ៍ចម្បងពីរគឺ ៖

### កង្វះអាហារូបត្ថម្ភស្ងួត ឬជំងឺម៉ារ៉ាស
(Dry Malnutrition ឬ Marasmus)



កុមារនេះមានតែស្បែកដណ្តប់ឆ្អឹងប៉ុណ្ណោះ

កុមារនេះមិនបានទទួលអាហារប្រភេទណាមួយបានគ្រប់គ្រាន់ទេ។ គេនិយាយថា **កុមារនេះមាន កង្វះអាហារូបត្ថម្ភស្ងួត ឬជំងឺម៉ារ៉ាស។** គេអាចនិយាយម៉្យាងទៀតថា កុមារនេះគ្មានអាហារបរិភោគ។ រាងកាយរបស់គាត់តូច ស្គម និងស្វិត។ គាត់នៅសល់តែស្បែកបន្តិចបន្តួចនិងឆ្អឹងប៉ុណ្ណោះ។

កុមារម្នាក់នេះត្រូវការអាហារជាច្រើន ជាពិសេសអាហារថាមពល។

## កង្វះអាហារូបត្ថម្ភសើម ឬជំងឺក្វាស្យូគ័រ ( Wet malnutrition ឬ Kwashiorkor )

ស្ថានភាពរបស់កុមារម្នាក់នេះ ហៅថា កង្វះអាហារូបត្ថម្ភសើម ព្រោះ**ជើងដៃនិងមុខរបស់គាត់ឡើងហើម។** បញ្ហានេះអាចកើតឡើងនៅពេលកុមារមិនបានបរិភោគអាហារជំនួយស្ថាបនារាងកាយ ឬប្រូតេអ៊ីនគ្រប់គ្រាន់។ ភាគច្រើនវាកើតឡើងនៅពេលកុមារមិនបានបរិភោគអាហារថាមពលគ្រប់គ្រាន់ ហើយរាងកាយរបស់កុមារបានប្រើប្រាស់ប្រូតេអ៊ីនគ្រប់ប្រភេទដែលគាត់បានបរិភោគ។




*ដំបូង កុមារចាប់ផ្តើមហើម។ រោគសញ្ញាដទៃទៀតចេញមកតាមក្រោយ។*

*កុមារនេះមានតែស្បែក ឆ្អឹង និងជាតិទឹកប៉ុណ្ណោះ។*

ការហូបសណ្តែក ឬអាហារផ្សេងទៀត ដែលបានរក្សាទុកនៅកន្លែងសើម ហើយមានដុះផ្សិតបន្តិចបន្តួចផងនោះ ក៏អាចជាដើមហេតុមួយនៃបញ្ហានេះដែរ។

កុមារនេះត្រូវការអាហារបន្ថែមនិងជាញឹកញាប់ ពោលគឺអាហារដែលសំបូរថាមពល និងអាហារដែលសំបូរប្រូតេអ៊ីន ( មើលទំ.១១១ )។

ម៉្យាងទៀត ត្រូវជៀសវាងអាហារដែលទុកយូរ និងអាហារដែលផ្អូម ឬដុះផ្សិត។

### ទម្រង់ផ្សេងៗទៀតនៃកង្វះអាហារូបត្ថម្ភ

ក្នុងចំណោមប្រជាជនក្រីក្រ ទម្រង់ញឹកញាប់បំផុតនៃកង្វះអាហារូបត្ថម្ភកម្រិតធ្ងន់ គឺដោយសារភាពអត់ឃ្លាន( ជំងឺម៉ារ៉ាស ) ឬខ្វះប្រូតេអ៊ីន( ជំងឺក្វាស្យូគ័រ )។ ទោះជាយ៉ាងនេះក្តី ក៏មានទម្រង់ផ្សេងៗទៀតនៃកង្វះអាហារូបត្ថម្ភ អាចកើតឡើងនៅពេលដែលអាហារដែលពួកគេបរិភោគនោះខ្វះប្រភេទខ្លះនៃវីតាមីនឬសារជាតុរ៉ែ។ នៅផ្នែកខាងក្រោយនៃជំពូកនេះ និងនៅក្នុងផ្នែកផ្សេងៗទៀតនៃសៀវភៅនេះ មានការពន្យល់លម្អិតអំពីបញ្ហាជាក់លាក់ជាច្រើននៃការខ្វះអាហារូបត្ថម្ភនេះ ៖

- **ជំងឺខ្វាក់មាន់** លើកុមារដែលមិនបានទទួលវីតាមីនអាគ្រប់គ្រាន់( មើលទំ.២២៦ )។
- **ជំងឺក្រិស** បណ្តាលមកពីខ្វះវីតាមីនដេ ( មើលទំ.១២៥ )។
- **បញ្ហាស្បែក**ផ្សេងៗ **ដំបៅនៅលើបបូរមាត់និងមាត់ ឬចេញឈាមតាមអញ្ចាញធ្មេញ** បណ្តាលមកពីការមិនបរិភោគបានគ្រប់គ្រាន់នូវ បន្លែ ផ្លែឈើ និងអាហារដែលមានវីតាមីនដទៃទៀត ( មើលទំ.២០៨និង២៣២ )។
- **ភាពស្លេកស្លាំង** លើមនុស្សដែលមិនបានទទួលជាតិដែកគ្រប់គ្រាន់( មើលទំ.១២៤ )។
- **ជំងឺពកក** បណ្តាលមកពីក្វះជាតិអ៊ីយ៉ូដ( មើលទំ.១៣០ )។



*ថតដោយដេប៉ូរ៉ា ខត*, NP

កុមារម្នាក់នេះរស់នៅជាមួយគ្រួសារក្រីក្រ ហើយមានអាហារូបត្ថម្ភមិនគ្រប់គ្រាន់។ ឪពុកគេខំធ្វើការយ៉ាងខ្លាំង ប៉ុន្តែគាត់រកប្រាក់មិនបានគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារឲ្យបានល្អឡើយ។ ក្រមរស្បែកនៅលើក្បាលកុមារម្នាក់នេះជាសញ្ញានៃ ជំងឺរលាកស្បែក( pellagra ) ដែលជាប្រភេទមួយនៃការខ្វះអាហារូបត្ថម្ភ។ កុមារម្នាក់នេះ ច្រើនតែបរិភោគពោត ហើយគ្មានអាហារបំប៉នគ្រប់គ្រាន់ឡើយ ដូចជា សណ្តែក ស៊ុត ផ្លែឈើ សាច់ និងបន្លែពណ៌បៃតង។

ម្តាយរបស់កុមារនេះមិនបានបំបៅកូនដោយទឹកដោះរបស់គាត់ទេ។ គាត់ផ្តល់ឲ្យកុមារម្នាក់នេះតែបបរពោតប៉ុណ្ណោះ។ ទោះបីអាហារនេះបានបំពេញក្រពះរបស់កុមារនេះក៏ដោយ វា មិនបានផ្តល់អាហារូបត្ថម្ភគ្រប់គ្រាន់ដើម្បីឲ្យកុមារលូត លាស់រឹងមាំទេ។ ជាលទ្ធផល កុមារអាយុ២ឆ្នាំម្នាក់នេះខ្វះអាហាររូបត្ថម្ភយ៉ាងធ្ងន់ធ្ងរ។ កុមារនេះមានរាងកាយតូចនិងស្គម ព្រមទាំងមានពោះប៉ោង ហើយកាយសម្បទានិងសតិបញ្ញាមានការរីកចំរើនយឺតជាងធម្មតាទៀតផង។ **ដើម្បីបង្ការបញ្ហានេះ កុមារត្រូវបរិភោគឲ្យបានត្រឹមត្រូវ។**

# វិធីបរិភោគជំប្រសើរ នៅពេលដែលអ្នកគ្មានប្រាក់ឬដីធ្លីច្រើន



មានហេតុផលជាច្រើនដែលទាក់ទងនឹងភាពអត់ឃ្លាន និងការខ្វះអាហារូបត្ថម្ភ។ ហេតុផលចម្បងមួយគឺភាពក្រីក្រ។ នៅក្នុងប្រទេសជាច្រើន មានមនុស្សមួយក្រុមតូចកាន់កាប់ទ្រព្យសម្បត្តិនិងដីធ្លីមួយភាគធំ។ ពួកគេអាចដាំដំណាំដូចជាកាហ្វេឬថ្នាំជក់ ដែលគេអាចលក់បានប្រាក់ជាច្រើន ប៉ុន្តែដំណាំទាំងនោះគ្មានគុណសម្បត្តិផ្នែកអាហារទេ។ ឬអ្នកក្រអាចធ្វើស្រែចម្ការ នៅលើដីធ្លីបន្តិចបន្តួចដែលខ្ចីគេ ហើយម្ចាស់ដីត្រូវទទួលផលមួយចំណែកធំពីផលដំណាំទាំងនោះទៀត។ **បញ្ហានៃភាពអត់ឃ្លាន និងការខ្វះអាហារូបត្ថម្ភ និងមិនអាចដោះស្រាយបានទាំងស្រុងទេ ប្រសិនបើមនុស្សយើងមិនទាន់បានរៀនចែករំលែកផលប្រយោជន៍គ្នាទៅវិញទៅមកដោយយុត្តិធម៌នោះ។**

ប៉ុន្តែមានវិធីជាច្រើនដែលប្រជាជនអាចធ្វើបាន ដើម្បីបរិភោគបានប្រសើរ ដោយចំណាយប្រាក់តិច ហើយការបរិភោគបានប្រសើរនេះ អាចផ្តល់នូវកម្លាំងដើម្បីឲ្យពួកគេក្រោកឈរឡើងទាមទារសិទ្ធិរបស់ពួកគេ។ នៅទំព័រ ជំ.១៣ និងជំ.១៤ ផ្នែក "ដំបូន្មានចំពោះភ្នាក់ងារសុខភាពភូមិ" អ្នកអាចឃើញសំណូមពរមួយចំនួនសម្រាប់បង្កើនការផលិតអាហារ។ ក្នុងនោះរួមមានការកែលម្អការប្រើប្រាស់ដីធ្លី តាមរយៈការ**ដាំដំណាំចម្លាស់ ការរៀបចំដី** និង**ប្រព័ន្ធបង្ហូរទឹក** ព្រមទាំងគំនិតអំពី**ការចិញ្ចឹមត្រី ចិញ្ចឹមឃ្មុំ ការរក្សាទុកផលិតផល** និង**ដាំដំណាំគ្រួសារ**។ ប្រសិនបើប្រជាជនក្នុងភូមិទាំងមូល ឬគ្រួសារមួយក្រុម ធ្វើការងារទាំងនេះជាមួយគ្នា នោះអាហារូបត្ថម្ភនឹងត្រូវបានកែលម្អយ៉ាងខ្លាំង។

នៅពេលដែលពិចារណាអំពីបញ្ហាអាហារនិងដីធ្លី ការសំខាន់គឺត្រូវចាំថាទំហំដីមួយប្លង់ អាចចិញ្ចឹមមនុស្សបានមួយក្រុមតែប៉ុណ្ណោះ។ ដោយមូលហេតុនេះហើយ ទើបប្រជាជនមួយចំនួនអះអាងថាគ្រួសារតូច រស់នៅបានល្អជាងគ្រួសារធំ។ ទោះជាយ៉ាងនេះក្តី សម្រាប់គ្រួសារក្រីក្រជាច្រើន ការមានកូនច្រើនគឺជាការចាំបាច់ផ្នែកសេដ្ឋកិច្ច។ នៅពេលដែលពួកគេមានអាយុ១០ឬ១២ឆ្នាំ កុមារក្នុងគ្រួសារក្រីក្រតែងតែអាចរកចំណូលឲ្យគ្រួសារបានច្រើនជាងការចំណាយទៅលើពួកគេ។ ការមានកូនច្រើន បង្កើនឱកាសដល់ឪពុកម្តាយក្នុងការទទួលបានការជួយជ្រោមជ្រែង និងការថែទាំផ្សេងៗនៅពេលដែលពួកគាត់មានវ័យចំណាស់។

ជារួម កង្វះសន្តិសុខសង្គមនិងសន្តិសុខសេដ្ឋកិច្ច ធ្វើឲ្យឪពុកម្តាយត្រូវការកូនច្រើន។ ដូច្នេះ ចម្លើយចំពោះការមានតុល្យភាពរវាងមនុស្សនិងដីធ្លី មិនស្ថិតលើការប្រាប់ប្រជាជនក្រីក្រឲ្យមានគ្រួសារតូចនោះទេ។ វាស្ថិតនៅលើការបែងចែកដីធ្លីដោយយុត្តិធម៌ ការបង់ថ្លៃឈ្នួលពលកម្មសមរម្យ និងការអនុវត្តន៍វិធានការផ្សេងៗទៀតដើម្បីជំនះភាពក្រីក្រ។ នៅពេលនោះហើយទើបប្រជាជនអាចផ្គត់ផ្គង់គ្រួសារតូចៗ និងមានសង្ឃឹមថាអាចទទួលបានតុល្យភាពយូរអង្វែងរវាងមនុស្ស និងដីធ្លី។ (ចំពោះការពិភាក្សាអំពីផែនការគ្រួសារ សូមអានជំពូកទី២០)។

នៅពេលដែលមិនទាន់មានប្រាក់ច្រើន ការសំខាន់គឺត្រូវចំណាយវាឲ្យបានត្រឹមត្រូវ។ នេះមានន័យថាជាការសហការ និងការសំឡឹងទៅអនាគត។ ជាញឹកញាប់ ឪពុកនៃគ្រួសារក្រីក្រតែងតែបានចំណាយប្រាក់ដែលមានបន្តិចបន្តួចទៅលើស្រា និងបារី ជាជាងការទិញអាហារល្អៗ ឬទិញមេមាន់មកចិញ្ចឹមដើម្បីយកស៊ុត ឬទិញអ្វីផ្សេងទៀតសម្រាប់កែលម្អសុខភាពគ្រួសារឡើយ។ ពេលខ្លះ បុរសដែលផឹកស្រាជាមួយគ្នា អាចជួបជុំគ្នានៅពេលដែលមិនស្រវឹង ដើម្បីពិភាក្សាអំពីបញ្ហាទាំងនេះ ហើយស្វែងរកដំណោះស្រាយដើម្បីឲ្យមានសុខភាពល្អវិញ។

ម៉្យាងទៀត ម្តាយមួយចំនួនទិញស្ករគ្រាប់ឬទឹកក្រូចកំប៉ុងឲ្យកូនរបស់គាត់ នៅពេលដែលគាត់អាចយកប្រាក់នោះទៅទិញស៊ុត ទឹកដោះគោ សណ្តែក ឬអាហារល្អៗផ្សេងទៀតវិញ។ ការធ្វើរបៀបនេះ កូនៗរបស់គាត់អាចមានសុខភាពល្អជាង ជាមួយទឹកប្រាក់ដដែលនោះ។ ពិភាក្សានិងរិះរកដំណោះស្រាយចំពោះបញ្ហាទាំងនេះជាមួយម្តាយទាំងឡាយ។



ទេ

*ប្រសិនបើអ្នកមានប្រាក់បន្តិចបន្តួច ហើយចង់ជួយឲ្យកូនរបស់អ្នកលូតលាស់រឹងមាំ ៖*
*កុំទិញទឹកស្ករគ្រាប់ ឬទឹកក្រូចឲ្យគាត់។ ទិញស៊ុតពីរ ឬគ្រាប់ធុញ្ញជាតិឲ្យគាត់វិញ។*

បាទ/ចាស់



# អាហារដែលល្អ ក្នុងតម្លៃថោក

មានមនុស្សជាច្រើនក្នុងលោកនេះ បរិភោគអាហារជាតិម្សៅយ៉ាងច្រើន ដោយមិនបានបន្ថែមអាហារជំនួយគ្រប់គ្រាន់ ដើម្បីផ្តល់បន្ថែមនូវថាមពល ការស្ថាបនារាងកាយ និងការការពារដែលពួកគេត្រូវការ។ មូលហេតុមួយផ្នែកនៃបញ្ហានេះ គឺដោយសារអាហារជំនួយមានតម្លៃថ្លៃ ជាពិសេសអាហារដែលបានមកពីសត្វ ដូចជាទឹកដោះគោ និងសាច់។

មានមនុស្សជាច្រើនពុំមានលទ្ធភាពទិញសាច់សត្វទេ។ សត្វទាំងឡាយត្រូវការការមានដីធ្លីជាច្រើន ដើម្បីឲ្យវាអាចផ្តល់ជាអាហារមកវិញ។ ជាធម្មតាគ្រួសារក្រីក្រអាចមានអាហារូបត្ថម្ភល្អ ប្រសិនបើពួកគេ**ដាំឬទិញអាហាររុក្ខជាតិដូចជាសណ្តែកគ្រប់ប្រភេទ ជាមួយនឹងអាហារចម្បងដូចជាពោត ឬអង្ករ ជាជាងការទិញសាច់សត្វថ្លៃៗដូចជាសាច់ជ្រូក សាច់គោ និងត្រី។**

**មនុស្សអាចមានកម្លាំងមាំមួន និងមានសុខភាពល្អ នៅពេលដែលជាតិប្រូតេអ៊ីន និងអាហារជំនួយដទៃទៀតរបស់ពួកគេ បានមកពីរុក្ខជាតិ។**

ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើទំនៀមទម្លាប់ និងសេដ្ឋកិច្ចគ្រួសារអាចធ្វើទៅបាន វាជាការល្អក្នុងការបរិភោគអាហារខ្លះដែលមានប្រភពពីសត្វ បើអាចមាន។ នេះដោយសារថាសូម្បីតែអាហាររុក្ខជាតិដែលសំបូរជាតិប្រូតេអ៊ីន (អាហារស្ថាបនារាងកាយ)ក៏ដោយ ក៏មិនមែនមានប្រូតេអ៊ីនគ្រប់ប្រភេទដែលរាងកាយត្រូវការនោះទេ។

ព្យាយាម**បរិភោគអាហាររុក្ខជាតិឲ្យបានច្រើនប្រភេទ។** ប្រភេទរុក្ខជាតិនីមួយៗផ្តល់ឲ្យរាងកាយនូវប្រូតេអ៊ីន វីតាមីន និងសារធាតុរ៉ែផ្សេងៗគ្នា។ ឧទាហរណ៍ សណ្តែករួមជាមួយពោត អាចបំពេញតម្រូវការរបស់រាងកាយបានប្រសើរជាងសណ្តែត ឬពោតតែមួយមុខ។ ហើយប្រសិនបើ មានការបន្ថែមបន្លែនិងផ្លែឈើផ្សេងទៀត នោះកាន់តែប្រសើរ។

ខាងក្រោមនេះគឺជាសំណូមពរមួយចំនួនដើម្បីទទួលបានប្រូតេអ៊ីន វីតាមីន និងសារធាតុរ៉ែ ក្នុងតម្លៃថោក។



១. **ទឹកដោះម្តាយ** គឺជាអាហារដែលចំណាយតិចបំផុត ជួយធ្វើឲ្យមានសុខភាពល្អ និងជាអាហារដែលមានគ្រប់សាធាតុទាំងអស់ សម្រាប់ទារក។ ម្តាយអាចបរិភោគអាហាររុក្ខជាតិឲ្យបានគ្រប់គ្រាន់ ហើយផលិតបានជាអាហារដែលល្អឥតខ្ចោះមួយសម្រាប់ទារក គឺទឹកដោះម្តាយ។ ការបំបៅកូនដោយទឹកដោះម្តាយ មិនគ្រាន់តែមានប្រយោជន៍ដល់ទារកប៉ុណ្ណោះទេ វាថែមទាំងជួយសន្សំប្រាក់កាស់ និងបង្ការជំងឺផ្សេងៗទៀតផង។



២. **ស៊ុតនិងសាច់មាន់ ៖** នៅប្រទេសជាច្រើន ស៊ុតគឺជាទម្រង់មួយនៃប្រូតេអ៊ីនរបស់សត្វដែលមានតម្លៃថោកនិងមានគុណភាពល្អបំផុត។ យើងអាចចម្អិនស៊ុតលាយជាមួយអាហារសម្រាប់ទារកដែលមិនអាចបៅទឹកដោះម្តាយបាន។ ឬអាចឲ្យទារកបរិភោគជាមួយទឹកដោះម្តាយ នៅពេលកុមារធំបន្តិច។

សំបកស៊ុតដែលចម្អិនឆ្អិន បុកឲ្យម៉ត់ រួចលាយជាមួយអាហារ អាចផ្តល់កាល់ស្យូមសម្រាប់ស្ត្រីមានផ្ទៃពោះដែលឈឺធ្មេញ រង្គើរធ្មេញ ឬឈឺចាប់សាច់ដុំ។



សាច់មាន់គឺជាទម្រង់មួយនៃប្រូតេអ៊ីនរបស់សត្វ ដែលល្អ និងមានតម្លៃថោកសមរម្យ ជាពិសេសចំពោះគ្រួសារដែលចិញ្ចឹមមាន់ដោយខ្លួនឯង។

៣. **ថ្លើម បេះដូង ក្រលៀន និងឈាមសត្វ ៖** ទាំងអស់នេះសំបូរប្រូតេអ៊ីន វីតាមីន និងជាតិដែក(សម្រាប់ភាពស្លេកស្លាំង) ហើយភាគច្រើនមានតម្លៃថោកជាងសាច់ផ្សេងៗទៀត។ ម៉្យាងទៀត **សាច់ត្រី**តែងតែមានតម្លៃថោកជាងសាច់ដទៃទៀត ហើយមានអាហារូបត្ថម្ភដូចគ្នា។



៤. **សណ្ដែកគ្រប់ប្រភេទ** ជាប្រភពប្រូតេអ៊ីនដ៏ល្អមួយ ដែលមានតម្លៃថោក។ បើទុកវាឲ្យមានដុះពន្លកបន្តិចមុននឹងយកទៅចម្អិននិងបរិភោគ នោះវាកាន់តែមានវីតាមីនច្រើន។ អាហារទារកអាចធ្វើពីសណ្ដែក ដោយចម្អិនវាឲ្យរលួយ រួចច្រោះយកសំបកវាចេញ ឬបកសំបកវាចេញ ហើយកិនវាឲ្យម៉ត់។

សណ្ដែកមិនត្រឹមតែជាប្រភេទប្រូតេអ៊ីនដែលមានតម្លៃថោកប៉ុណ្ណោះទេ។ ការដាំសណ្ដែកទាំងនេះធ្វើឲ្យដីល្អ និងធ្វើឲ្យដំណាំផ្សេងៗទៀត លូតលាស់យ៉ាងល្អ នៅពេលក្រោយ។ ដោយហេតុផលនេះហើយទើបការដាំដំណាំចម្លាស់ និងដំណាំចម្រុះ គឺជាគំនិតដ៏ល្អមួយ។ (មើលទំ.៣១៣)។



៥. **បន្លែបៃតងចាស់** មានជាតិដែក វីតាមីនAជាច្រើន និងប្រូតេអ៊ីនមួយចំនួន។ ស្លឹកដំឡូង ស្លឹកសណ្ដែក ស្លឹកល្ពៅ ស្លឹកម្រុំ គឺជាអាហារដែលមានអាហារូបត្ថម្ភយ៉ាងពិសេស។ គេអាចយកវាទៅហាលឲ្យស្ងួត កិនឲ្យម៉ត់ ហើយលាយជាមួយបបរសម្រាប់ទារក។

*ចំណាំ ៖* បន្លែបៃតងខ្ចីដូចជាសាលាដ ស្ពៃស មានអាហារូបត្ថម្ភតិចបន្លែបៃតងចាស់។ ដូច្នេះ ជាការល្អគួរដាំបន្លែដែលមានស្លឹកពណ៌បៃតងចាស់។



៦. **ស្លឹកដំឡូងមី**មានជាតិប្រូតេអ៊ីននិងវីតាមីន ប្រាំពីរដងច្រើនជាងមើមរបស់វា។ បើបរិភោគមើមជាមួយនិងស្លឹក នោះវានឹងបន្ថែមគុណភាពអាហារដោយគ្មានការចំណាយប្រាក់បន្ថែម។ ស្លឹកខ្ចីៗ គឺជាអាហារល្អបំផុត។



៧. **ពោតជ្រលក់ក្រូចឆ្មា ៖** នៅពេលជ្រលក់ជាមួយក្រូចឆ្មា (ដូចដែលជនជាតិអាមេរិកឡាទីនចូលចិត្តធ្វើ) មុននឹងយកទៅស្ងោរ ពោតនឹងមានជាតិកាល់ស្យូមកាន់តែច្រើន។ ការជ្រលក់ក្រូចឆ្មានេះ ក៏ធ្វើឲ្យរាងកាយងាយប្រើប្រាស់នូវវីតាមីន(niacin)និងប្រូតេអ៊ីនផងដែរ។



៨. **ស្រូវ ស្រូវសាលី និងគ្រាប់ធញ្ញជាតិផ្សេងៗ** ផ្ដល់អាហារូបត្ថម្ភបន្ថែម បើគេកិនដោយទុកសំបក របស់វា។ អង្ករសំរូបនិងអង្ករសាលីសំរូបមានប្រូតេអ៊ីន វីតាមីន សារធាតុរ៉ែច្រើនជាងអង្ករសំរិត។

ចំណាំ ៖ រាងកាយងាយប្រើប្រាស់ប្រូតេអ៊ីននៅក្នុងស្រូវសាលី ស្រូវ ពោត និងគ្រាប់ធញ្ញជាតិដទៃទៀត កាលណាគេបរិភោគវាជាមួយសណ្ដែក។



៩. **ចម្អិនបន្លែ អង្ករ និងអាហារផ្សេងទៀត ជាមួយទឹក។ កុំចម្អិនយូរពេក។** ការធ្វើរបៀបនេះ មិនសូវបាត់បង់វីតាមីននិងប្រូតេអ៊ីន។ បរិភោគទឹកបបរនោះ ឬប្រើវាជាទឹកស៊ុប ឬបរិភោគវាជាមួយអាហារផ្សេងទៀត។



១០. **ផ្លែឈើព្រៃ** និងផ្លែឈើតូចៗ សំបូរវីតាមីនសេ ព្រមទាំងជាតិស្ករធម្មជាតិទៀតផង។ វាផ្ដល់វីតាមីននិងថាមពលបន្ថែម។ (តែសូមប្រយ័ត្ន កុំហូបផ្លែឈើពុល)។



១១. **ការដាំស្លក្នុងឆ្នាំងដែក** ឬដាក់ដែកចាស់ៗ ឬដែកមួយដុំតូចទៅក្នុងឆ្នាំង នៅពេលចម្អិនសណ្ដែកឬអាហារដទៃទៀត អាចជួយបន្ថែមជាតិដែកទៅក្នុងអាហារ ព្រមទាំងជួយបង្ការភាពស្លេកស្លាំងផង។ អ្នកក៏អាចបន្ថែមប៉េងប៉ោះផងដែរ ដើម្បីបានជាតិដែកបន្ថែមទៀត។

ប្រភពមួយទៀតនៃជាតិដែកគឺ យកដែកគោលទៅដាក់ក្នុងទឹកក្រូចឆ្មាពីរបីម៉ោង រួចធ្វើទឹកក្រូចឆ្មាស្ករសជាមួយនឹងទឹកនោះ រួចផឹក។



១២. នៅប្រទេសមួយចំនួនមាន**អាហារផ្សំសម្រាប់កុមារក្នុងតម្លៃថោក** ដែលផ្សំឡើងដោយសណ្តែកសៀង គ្រាប់កប្បាស ទឹកដោះគោ ឬត្រីងៀត។ អាហារផ្សំខ្លះមានរសជាតិឆ្ងាញ់ជាងអាហារផ្សំខ្លះទៀត ប៉ុន្តែជាទូទៅវាជាអាហារដែលមានគុណភាពល្អ។ នៅពេលលាយជាមួយបបរ គ្រាប់ធញ្ញជាតិផ្សិន ឬជាមួយអាហារទារកផ្សេងៗទៀត វាបង្កើនអាហារូបត្ថម្ភបន្ថែមក្នុងតម្លៃថោក។




## តើវីតាមីនមាននៅឯណា? នៅក្នុងថ្នាំគ្រាប់ ថ្នាំចាក់ ថ្នាំស៊ីរ៉ូ ឬនៅក្នុងអាហារ?

អ្នកដែលបរិភោគអាហារច្រើនមុខបានត្រឹមត្រូវ ដោយរួមបញ្ចូលទាំងបន្លែនិងផ្លែឈើ ទទួលបានវីតាមីនគ្រប់យ៉ាងដែលរាងកាយត្រូវការ។ ការបរិភោគបានត្រឹមត្រូវ តែងតែល្អជាងការទិញថ្នាំវីតាមីនគ្រាប់ ថ្នាំចាក់ ថ្នាំស៊ីរ៉ូ ឬថ្នាំកម្លាំងជានិច្ច។

ត្រឹមត្រូវ



**ប្រសិនបើអ្នកចង់បានវីតាមីន ទិញស៊ុត ឬអាហារបំប៉នផ្សេងៗ ជាជាងទិញថ្នាំលេប ឬថ្នាំចាក់។**

មិនត្រឹមត្រូវ



ជួនកាលអាហារបំប៉នមិនសូវសំបូរទេ។ ប្រសិនបើមនុស្សម្នាក់កំពុងមានការខ្វះអាហារូបត្ថម្ភ ព្យាយាមបរិភោគអាហារឲ្យបានត្រឹមត្រូវតាមដែលអាចធ្វើបាន ហើយប្រហែលជាអាចប្រើថ្នាំវីតាមីនបន្ថែមទៀត។

ថ្នាំវីតាមីនគ្រាប់ក៏មានប្រសិទ្ធភាពដូចថ្នាំចាក់ដែរ តែមានតម្លៃថោកជាង និងមិនសូវមានគ្រោះថ្នាក់ដូចថ្នាំចាក់ទេ។ **កុំចាក់ថ្នាំវីតាមីន! ជាការល្អគួរប្រើវាលេបតាមមាត់វិញ ជាពិសេសវីតាមីនដែលមានទម្រង់ជាអាហារបំប៉ន។**

**ប្រសិនបើអ្នកទិញថ្នាំវីតាមីន** ត្រូវប្រាកដថាថ្នាំនោះមានវីតាមីន និងសារធាតុរ៉ែទាំងអស់នេះ ៖

- នីយ៉ាស៊ីន (នីយ៉ាស៊ីណាមីដ)
- វីតាមីន បេ១ (ទីយ៉ាមីន)
- វីតាមីន បេ២(រីបូហ្វ្លាវីន)
- ជាតិដែក(ហ្វេរ៉ូស៊ុលហ្វាត)ជាពិសេសសម្រាប់ស្ត្រីមានផ្ទៃពោះ។ (ថ្នាំមុលទីវីតាមីន មិនមានជាតិដែកគ្រប់គ្រាន់សម្រាប់អ្នកមានភាពស្លេកស្លាំងទេ។ សម្រាប់ពួកគេ ថ្នាំជាតិដែកមានប្រយោជន៍ជាង)

បន្ថែមពីនេះទៀត មនុស្សមួយចំនួនត្រូវការ ៖

- អាស៊ីតហ្វូលិក (ហ្វូលីស៊ីន) សម្រាប់ស្ត្រីមានផ្ទៃពោះ
- វីតាមីនអា } សម្រាប់កុមារៗ
- វីតាមីនសេ(អាស៊ីតអាស្កូប៊ិក) } សម្រាប់កុមារៗ
- វីតាមីនដេ
- អ៊ីយ៉ូដ (នៅកន្លែងដែលមានជំងឺពក កច្រើន)
- វីតាមីនបេ៦(ពីរីដុកស៊ីន) សម្រាប់កុមារតូចៗ និងអ្នកលេបថ្នាំរបេង។
- កាល់ស្យូម សម្រាប់កុមារ និងស្ត្រីបំបៅដោះកូន ដែលមិនបានទទួលកាល់ស្យូមគ្រប់គ្រាន់នៅក្នុងអាហារ ដូចជាទឹកដោះគោ ឬអាហារដែលមានលាយក្រូចឆ្មា។

# អ្វីដែលត្រូវចៀសវាងនៅក្នុងរបបអាហាររបស់យើង

មនុស្សជាច្រើនជឿថាមានអាហារមួយចំនួនធ្វើឲ្យពួកគេមានគ្រោះថ្នាក់ ឬជឿថាពួកគេមិនគួរបរិភោគអាហារទេនៅពេលមានជំងឺ។ ពួកគេអាចគិតថាអាហារខ្លះជាអាហារក្តៅ និងខ្លះទៀតជាអាហារត្រជាក់ ហើយពួកគេមិនបរិភោគអាហារក្តៅ នៅពេលមានជំងឺក្តៅ ឬមិនបរិភោគអាហារត្រជាក់ពេលមានជំងឺត្រជាក់។ ឬពួកគេអាចជឿថា មានអាហារជាច្រើនមុខជាអាហារមិនល្អសម្រាប់ស្ត្រីដែលទើបសម្រាលកូនរួច។ ជំនឿខ្លះនៃជំនឿទាំងនេះ សមហេតុផលដែរ ប៉ុន្តែជំនឿខ្លះទៀតធ្វើឲ្យមានគ្រោះថ្នាក់ច្រើនជាងផ្តល់ផលល្អ។ ជាញឹកញាប់ អាហារដែលពួកគេគិតថាគួរចៀសវាង នៅពេលមានជំងឺ គឺជាអាហារល្អបំផុតដែលពួកគេត្រូវការដើម្បីឲ្យឆាប់ជាសះស្បើយឡើងវិញ។

មនុស្សដែលមានជំងឺត្រូវការអាហារបំប៉នច្រើនជាងមនុស្សដែលមានសុខភាពល្អទៅទៀត។ យើងមិនគួរបារម្ភច្រើនពេកចំពោះអាហារដែលអាចធ្វើឲ្យមានគ្រោះថ្នាក់ដល់អ្នកជំងឺនោះទេ ហើយគួរគិតអំពីអាហារដែលជួយឲ្យគាត់មានសុខភាពល្អឡើងវិញ។ ឧទាហរណ៍ អាហារសំបូរថាមពល រួមជាមួយផ្លែឈើ បន្លែ គ្រាប់ធញ្ញជាតិ ទឹកដោះគោ សាច់ស៊ុត និងត្រី។ ជាទូទៅ ៖

**អាហារទាំងឡាយដែលល្អសម្រាប់យើងនៅពេលមានសុខភាពល្អ**
**ក៏នៅតែជាអាហារល្អសម្រាប់យើង នៅពេលដែលមានជំងឺដែរ។**

ដូចគ្នានេះដែរ អាហារដែលធ្វើឲ្យយើងមានគ្រោះថ្នាក់នៅពេលមានសុខភាពល្អ ធ្វើឲ្យមានគ្រោះថ្នាក់កាន់តែខ្លាំងនៅពេលយើងមានជំងឺ។ ដូច្នេះ ត្រូវជៀសវាងរបស់ទាំងនេះ ៖




- ស្រាធ្វើឲ្យមានជំងឺយ៉ាងធ្ងន់ធ្ងរដល់ថ្លើម ក្រពះ បេះដូង និងសរសៃប្រសាទ។ វាក៏បណ្តាលឲ្យមានបញ្ហាដល់សង្គមទៀតផង។
- ការជក់បារីអាចបណ្តាលឲ្យមានការក្អករ៉ាំរ៉ៃ ឬជំងឺមហារីកសួត និងបញ្ហាផ្សេងៗទៀត(មើលទំ.១៤៩)។ ការជក់បារីមានផលប៉ះពាល់កាន់តែខ្លាំងចំពោះអ្នកមានជំងឺសួត ដូចជាជំងឺរបេង ជំងឺហឺត និងជំងឺរលាកទងសួត។
- ការបរិភោគអាហារសំបូរខ្លាញ់ ឬកាហ្វេច្រើន អាចធ្វើឲ្យដំបៅក្រពះ និងជំងឺផ្សេងៗទៀតនៃបំពង់រំលាយអាហារកាន់តែធ្ងន់ធ្ងរ។
- ការបរិភោគស្ករនិងជាតិផ្អែមច្រើនពេក កាត់បន្ថយការឃ្លានអាហារ ព្រមទាំងធ្វើឲ្យពុកធ្មេញទៀតផង។ ទោះជាយ៉ាងនេះក្តី ជាតិស្ករខ្លះរួមជាមួយអាហារផ្សេងៗទៀត អាចជួយផ្តល់ថាមពលដែលត្រូវការដល់អ្នកជំងឺ ឬកុមារដែលមានការខ្វះអាហារូបត្ថម្ភ។

មានជំងឺមួយចំនួនតូច តម្រូវឲ្យតមអាហារខ្លះ។ ឧទាហរណ៍ អ្នកមានជំងឺលើសឈាម ជំងឺបេះដូង ឬហើមជើង គួរប្រើអំបិលបន្តិចបន្តួច ឬគ្មានជាតិប្រៃតែម្តង។ ការបរិភោគអំបិលច្រើនពេក មិនល្អចំពោះមនុស្សគ្រប់គ្នា។ អ្នកមានជំងឺដំបៅក្រពះ និងជំងឺទឹកនោមផ្អែម ក៏ត្រូវមានរបបអាហារពិសេសដែរ(មើលទំ.១២៧និង១២៨)។

# របបអាហារល្អបំផុតសម្រាប់កុមារតូចៗ

## សម្រាប់អាយុ៦ខែដំបូង



**ចំពោះកុមារអាយុក្រោម៦ខែ ត្រូវឲ្យបៅទឹកដោះម្ដាយតែមួយមុខគត់ ហើយមិនត្រូវផ្ដល់អ្វីផ្សេងទៀតទេ។ ទឹកដោះម្ដាយល្អជាងអាហារផ្សេងៗទៀតសម្រាប់ទារក ឬទឹកដោះគោដែលអ្នកអាចទិញបាន។** ទឹកដោះម្ដាយជួយការពារទារកពីជំងឺរាក និងជំងឺឆ្លងជាច្រើនទៀត។ ជាការល្អបំផុត មិនត្រូវផ្ដល់ទឹកឬទឹកតែបន្ថែមទៅឲ្យទារកទេ ទោះជាស្ថិតក្នុងអាកាសធាតុក្ដៅក៏ដោយ។

ស្ត្រីមួយចំនួនឈប់បំបៅដោះកូនឆាប់ពេក ព្រោះគាត់គិតថាទឹកដោះរបស់គាត់មិនល្អ គ្រប់គ្រាន់សម្រាប់កូនរបស់គាត់ទេ ឬថាដោះរបស់គាត់មិនបង្កើតទឹកដោះបានគ្រប់គ្រាន់។ **ទោះជាយ៉ាងណាក៏ដោយ ទឹកដោះម្ដាយតែងតែមានសារជាតិបំប៉នល្អសម្រាប់កូនគាត់ជានិច្ច ទោះជាគាត់ស្គម ឬខ្សោយកម្លាំងក៏ដោយ។**

**ប្រសិនបើម្ដាយមានជំងឺអេដស៍ ជួនកាលគាត់អាចចម្លងជំងឺនេះទៅទារក តាមរយៈទឹកដោះរបស់គាត់។** ប៉ុន្តែបើគាត់គ្មានទឹកស្អាតទេ នោះកូនរបស់គាត់ទំនងជាអាចស្លាប់ដោយសារជំងឺរាក ការខ្សោះជាតិទឹក និងកង្វះអាហារូបត្ថម្ភ ជាងជំងឺអេដស៍។ មានតែអ្នកទេ ដែលអាចវាយតម្លៃអំពីស្ថានភាពនៅក្នុងផ្ទះ និងក្នុងសហគមន៍របស់អ្នកបាន ហើយសម្រេចថាត្រូវធ្វើយ៉ាងដូចម្ដេចនោះ។

ម្ដាយស្ទើរតែទាំងអស់អាចផលិតទឹកដោះដែលកូនរបស់គាត់ត្រូវការ ៖

- វិធីល្អបំផុតសម្រាប់ធ្វើឲ្យម្ដាយបន្តផលិតទឹកដោះបានគ្រប់គ្រាន់ គឺ**ត្រូវបំបៅដោះកូនឲ្យបានញឹកញាប់ បរិភោគអាហារឲ្យបានត្រឹមត្រូវ និងផឹកទឹកឲ្យបានច្រើន។**
- មិនត្រូវផ្ដល់អាហារផ្សេងទៀតដល់ទារក ក្រៅពីទឹកដោះម្ដាយ មុនពេលដែលទារកមានអាយុ៦ខែ ហើយ**ត្រូវឲ្យទារកបៅដោះម្ដាយសិន មុននឹងឲ្យអាហារផ្សេងៗទៀត។**
- ប្រសិនបើដោះរបស់ម្ដាយអាចផលិតទឹកដោះបានតិចតួច ឬគ្មានទឹកដោះសោះ គាត់គួរបន្តបរិភោគឲ្យបានត្រឹមត្រូវ ផឹកទឹកឲ្យបានច្រើន ហើយ**ឲ្យទារកជញ្ជក់ដោះរបស់គាត់ឲ្យបានញឹកញាប់។** បន្ទាប់ពីបានបំបៅដោះរួច ផ្ដល់ឲ្យកុមារ នូវប្រភេទទឹកដោះផ្សេងទៀត ដោយប្រើពែង (មិនមែនប្រើដបបៅទេ) ដូចជាទឹកដោះគោ ឬពពែដែលចម្អិន ទឹកដោះគោកំប៉ុង ឬម្សៅទឹកដោះគោ។ (មិនត្រូវប្រើទឹកដោះគោខាប់ទេ)។ បន្ថែមស្ករឬប្រេងបន្ថែមបន្តិចបន្តួចទៅក្នុងប្រភេទទឹកដោះទាំងនេះ។

**ចំណាំ ៖** ទោះជាប្រើប្រភេទទឹកដោះណាមួយក៏ដោយ គួរបន្ថែមទឹកឆ្អិនត្រជាក់ខ្លះដែរ។




ប្រសិនបើប្រើទឹកដោះគ្មានជាតិខ្លាញ់ បន្ថែមប្រេង១ស្លាបព្រា។

- បើអាច ចម្អិនទឹកដោះគោ ជាមួយទឹក។ **ដើម្បីឲ្យមានសុវត្ថិភាព គួរបញ្ចុកទារកដោយប្រើពែង (ឬពែង និងស្លាបព្រា) ជាជាងការប្រើដបបៅ។** ដបបៅ និងក្បាលដោះរបស់ដប ពិបាកនឹងថែរក្សាអនាម័យណាស់ ហើយអាចបណ្ដាលឲ្យ មានការបង្ករោគ និងជំងឺរាកទៀតផង(មើលទំ.១៥៤)។ បើប្រើដបបៅ ត្រូវស្ងោរដប និងក្បាលដោះរបស់ដប រាល់ពេល មុនពេលបំបៅទារក។
- ប្រសិនបើអ្នកមិនអាចទិញទឹកដោះគោឲ្យកូនបាន អ្នកអាចធ្វើបបរពីអង្ករ ពោត ឬគ្រាប់ធញ្ញជាតិផ្សេងទៀត។ បន្ថែមឲ្យកុមារនូវសណ្ដែកបកសំបក ស៊ុត សាច់មាន់ សាច់ ឬជាតិប្រូតេអ៊ីនផ្សេងទៀត។ កិនបបរនេះឲ្យម៉ត់ ហើយបញ្ចុកកុមារដូចទឹកដែរ។ ប្រសិនបើអាច បន្ថែមស្ករឬប្រេងបន្តិច។

> *សូមប្រយ័ត្ន ៖* **ទឹកបបរ ឬបបរពោតតែមួយមុខ មិនគ្រប់គ្រាន់សម្រាប់ទារកទេ។ ទារកនឹងមិនលូតលាស់បានល្អទេ។ ទារកអាចងាយកើតជំងឺផ្សេងៗ ហើយអាចស្លាប់បាន។ ទារកត្រូវការអាហារចម្បង និងអាហារជំនួយបន្ថែម។**

### ពីអាយុ៦ខែ ទៅ១ឆ្នាំ

១. **បន្តផ្តល់ទឹកដោះម្តាយដល់កុមារ** ប្រសិនបើអាច បន្តរហូតដល់កុមារអាយុ២ឬ៣ឆ្នាំ។

២. នៅពេលកុមារមានអាយុ៦ខែ **ចាប់ផ្តើមផ្តល់អាហារដទៃទៀតបន្ថែមទៅលើទឹកដោះម្តាយ។** បំបៅដោះមុនជានិច្ច បន្ទាប់មកទើបឲ្យអាហារផ្សេងទៀត តាមក្រោយ។ ជាការល្អ គួរចាប់ផ្តើមពីបបរដែលធ្វើពីអាហារចម្បង (ទំ.១១១) ដូចជា អង្ករ ឬពោត។ បន្ទាប់មកចាប់ផ្តើមបន្ថែមប្រេងបន្តិចដើម្បីបង្កើនថាមពលឲ្យកុមារ។ ពីរបីថ្ងៃក្រោយមក ចាប់ផ្តើមបន្ថែម**អាហារជំនួយផ្សេងទៀត** (មើលទំ.១១០)។ ប៉ុន្តែ **អាហារថ្មីៗត្រូវចាប់ផ្តើមក្នុងបរិមាណបន្តិចបន្តួច សិន** ហើយបន្ថែមតែមួយមុខប៉ុណ្ណោះក្នុងមួយពេល បើមិនដូច្នេះទេកុមារអាចមានការពិបាកក្នុងការរំលាយអាហារ។ **អាហារថ្មីៗទាំងនេះ ត្រូវចម្អិនឲ្យឆ្អិនល្អ ហើយកិនឲ្យហ្មត់។** ដំបូងគេអាចលាយវាជាមួយនឹងទឹកដោះម្តាយបន្តិចបន្តួច ដើម្បីឲ្យកុមារស្រួលលេប។

៣. រៀបចំអាហារដែលមានតម្លៃថោកតែមានអាហារូបត្ថម្ភសម្រាប់ទារក ដោយបន្ថែមអាហារជំនួយទៅក្នុងអាហារចម្បង(មើលទំ.១១០)។ ជាការសំខាន់គឺត្រូវបន្ថែមអាហារដែលផ្តល់ថាមពលបន្ថែម(ដូចជាប្រេងបន្លែជាដើម) ហើយបើអាច បន្ថែមជាតិដែក(ដូចជាបន្លែពណ៌បៃតងចាស់)។

សូមចាំថា ក្រពះរបស់កុមារមានទំហំតូច ហើយមិនអាចផ្ទុកអាហារបានច្រើនក្នុងពេលតែមួយទេ។ ដូច្នេះ **ត្រូវបញ្ចុកកុមារឲ្យបានញឹកញាប់** ហើយ**បន្ថែមអាហារជំនួយដែលសំបូរថាមពល** ក្នុងអាហារចម្បង ៖



*ការបន្ថែមប្រេងមួយស្លាបព្រាទៅក្នុងអាហាររបស់កុមារ មានន័យថាកុមារត្រូវបរិភោគតែ៣/៤នៃអាហារចម្បងប៉ុណ្ណោះ ដើម្បីបំពេញតម្រូវការថាមពលរបស់គេ។ ប្រេងដែលបន្ថែមនោះ ជួយឲ្យកុមារបានទទួលថាមពល(កាឡូរី)គ្រប់គ្រាន់នៅពេលក្រពះរបស់គេពេញ។*

ប្រយ័ត្ន ៖ រយៈពេលដែលកុមារអាចក្លាយជាមានការខ្វះអាហារូបត្ថម្ភបំផុត គឺនៅពេលកុមារមានអាយុពី៦ខែ ទៅ២ឆ្នាំ។ នេះដោយសារតែទឹកដោះម្តាយតែមួយមុខមិនអាចផ្តល់ថាមពលគ្រប់គ្រាន់ដល់កុមារ បន្ទាប់ពីកុមារមានអាយុលើសពី៦ខែ។ កុមារត្រូវការអាហារបន្ថែមផ្សេងៗទៀត ប៉ុន្តែជួនកាលអាហារដែលបន្ថែមនោះ គ្មានថាមពលគ្រប់គ្រាន់ដដែល។ បើម្តាយឈប់បំបៅដោះកូនក្នុងពេលនេះទៀត កុមារនោះរឹតតែទំនងជានឹងក្លាយជាមានការខ្វះអាហារូបត្ថម្ភថែមទៀត។

ដើម្បីឲ្យកុមារដែលស្ថិតក្នុងវ័យនេះ មានសុខភាពល្អ យើងគួរ ៖

- ឲ្យកុមារបៅដោះឲ្យបានច្រើនដូចកាលពីមុន
- ឲ្យអាហារបំប៉នផ្សេងៗទៀត ដោយចាប់ផ្តើមបន្តិចម្តងៗ
- បញ្ចុកអាហារដល់កុមារយ៉ាងតិច៥ដងក្នុងមួយថ្ងៃ ហើយឲ្យចំណីផ្សេងៗទៀត នៅចន្លោះពេលបញ្ចុកអាហារទាំងនោះ
- ប្រាកដថាអាហាររបស់កុមារមានអនាម័យ និងត្រូវបានចម្អិនថ្មីៗ
- ច្រោះ ឬចម្អិនទឹកសម្រាប់ឲ្យកុមារផឹក
- រក្សាអនាម័យដល់កុមារ និងបរិស្ថានជុំវិញកុមារ
- នៅពេលមានជំងឺ ផ្តល់អាហារ ផ្តល់អាហារបន្ថែមឲ្យបានត្រឹមត្រូវ និងញឹកញាប់ ហើយផ្តល់ទឹកឲ្យកុមារផឹកឲ្យបានច្រើន។



**ចំពោះម្តាយដែលផ្ទុកមេរោគអេដស៍ ៖** ក្រោយរយៈពេល៦ខែ កូនរបស់អ្នកនឹងលូតលាស់ធំជាងមុន និងមាំមួនជាងមុន ព្រមទាំងមានការប្រឈមនឹងមានគ្រោះថ្នាក់នៃការស្លាប់ដោយសារជំងឺរាក តិចជាងមុន។ ប្រសិនបើអ្នកបានបំបៅដោះកូន ពេលនេះអ្នកគួរប្តូរទៅឲ្យបៅទឹកដោះផ្សេងវិញ និងបញ្ចុកអាហារផ្សេងៗទៀត។ តាមវិធីនេះ កុមារមិនសូវមានការ ប្រឈមនឹងការឆ្លងមេរោគអេដស៍ពីម្តាយរបស់វា។

**កុមារអាយុ១ឆ្នាំ និងលើសពីនេះ**

បន្ទាប់ពីមានអាយុ១ឆ្នាំ កុមារអាចបរិភោគ**អាហារផ្សេងៗដូចមនុស្សធំដែរ ប៉ុន្តែគួរបន្តការបៅដោះម្តាយតទៅទៀត** (ឬផឹកទឹកដោះគោ តាមដែលអាចធ្វើបាន)។

ជារៀងរាល់ថ្ងៃ ព្យាយាមផ្តល់ឲ្យកុមារនូវអាហារចម្បងដែលមនុស្សទូទៅបរិភោគ រួមជាមួយអាហារជំនួយដែលផ្តល់ថាមពល វីតាមីន ជាតិដែក និងសារធាតុរ៉ែបន្ថែម(បង្ហាញនៅទំ.១១១) ដើម្បីឲ្យកុមារលូតលាស់មាំមួន និងមានសុខភាពល្អ។

ដើម្បីឲ្យប្រាកដថាកុមារមានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ឲ្យកុមារបរិភោគក្នុងចានផ្ទាល់ខ្លួនរបស់វា ហើយឲ្យវាបរិភោគដោយខ្លួនឯង តាមដែលវាចង់។

**កុមារ និងស្ករគ្រាប់ ៖** កុំទម្លាប់ឲ្យកុមារញ៉ាំស្ករគ្រាប់ និងស្ករផ្សេងៗ ឬទឹកក្រូចច្រើនពេក។ នៅពេលកុមារញ៉ាំស្ករគ្រាប់ច្រើនពេក នោះគេនឹងមិនសូវចង់បរិភោគអាហារផ្សេងទៀតដែលរាងកាយត្រូវការនោះទេ។ ម្យ៉ាងទៀត ជាតិស្ករក៏មិនល្អសម្រាប់ធ្មេញរបស់គេផងដែរ។

ទោះជាយ៉ាងនេះក្តី នៅពេលការផ្គត់ផ្គង់អាហារមានកំណត់ ឬនៅពេលអាហារចម្បងមានជាតិទឹកឬសរសៃច្រើន ការបន្ថែមស្ករនិងប្រេងបន្តែបន្តិចទៅក្នុងអាហារចម្បងនោះ អាចផ្តល់ថាមពលបន្ថែម ព្រមទាំងធ្វើឲ្យកុមារទទួលបានប្រយោជន៍ពេញលេញពីប្រូតេអ៊ីននៅក្នុងអាហារដែលគេបរិភោគនោះ។

របបអាហារដែលល្អបំផុតសម្រាប់កុមារតូចៗ






# គំនិតប្រកបដោយគ្រោះថ្នាក់អំពីរបបអាហារ

**១. របបអាហាររបស់ស្ត្រីបន្ទាប់ពីសម្រាលកូន**

នៅតំបន់ជាច្រើន មានជំនឿប្រកបដោយគ្រោះថ្នាក់ដែលថាស្ត្រីដែលទើបសម្រាលកូនរួច មិនគួរបរិភោគអាហារមួយចំនួន។ ការតមអាហារតាមបែបបុរាណនេះ ដែលហាមឃាត់ស្ត្រីមិនឲ្យបរិភោគអាហារខ្លះនៃអាហារបំប៉នល្អៗ និងដែលអនុញ្ញាតឲ្យស្ត្រីបរិភោគតែអាហារដូចជា គ្រាប់ធញ្ញជាតិ មី ឬទឹកបបរនោះ បានធ្វើឲ្យស្ត្រីដែលទើបសម្រាលកូនរួចខ្សោយកម្លាំង និងមានភាពស្លេកស្លាំង។ បញ្ហានេះ ថែមទាំងអាចធ្វើឲ្យស្ត្រីស្លាប់ ដោយវាបានកាត់បន្ថយសមត្ថភាពរបស់ស្ត្រីក្នុងការទប់ទល់នឹងការធ្លាក់ឈាម និងការបង្ករោគផ្សេងៗ។

**បន្ទាប់ពីសម្រាលកូន ម្តាយត្រូវបរិភោគអាហារបំប៉នជាច្រើន**
**តាមដែលគាត់អាចបរិភោគបាន។**

ដើម្បីមានលទ្ធភាពប្រឆាំងនឹងជំងឺ ឬការធ្លាក់ឈាម និងដើម្បីផលិតទឹកដោះឲ្យបានគ្រប់គ្រាន់សម្រាប់ទារក ស្ត្រីបន្ទាប់ពីសម្រាលកូនគួរបរិភោគអាហារចម្បង រួមជាមួយអាហារស្ថាបនារាងកាយឲ្យបានគ្រប់គ្រាន់ ដូចជាសណ្តែក ស៊ុត សាច់មាន់ ហើយប្រសិនបើមាន អាហារដែលផលិតពីទឹកដោះ សាច់ និងត្រី។ គាត់ក៏ត្រូវការអាហារការពារដូចជាផ្លែឈើនិងបន្លែ និងអាហារថាមពល(ប្រេងនិងខ្លាញ់)ផងដែរ។ អាហារទាំងអស់នេះមិនបង្កឲ្យមានគ្រោះថ្នាក់ដល់គាត់ទេ វានឹងជួយការពារគាត់ និងធ្វើឲ្យគាត់រឹងមាំ។

*នេះគឺជាស្ត្រីម្នាក់មានសុខភាពល្អម្នាក់ ដែលបានបរិភោគអាហារបំប៉នជាច្រើនប្រភេទ បន្ទាប់ពីសម្រាលកូនរួច*



*នៅក្នុងនេះគឺជាស្ត្រីម្នាក់ដែលមានការភ័យខ្លាចក្នុងការបរិភោគអាហារបំប៉ន បន្ទាប់ពីសម្រាលកូនរួច*



២. **ជាការមិនពិតទេដែលថាផ្លែក្រូច ផ្លែត្របែក ឬផ្លែឈើដ៏ទៃទៀត មិនល្អចំពោះអ្នកមានជំងឺផ្តាសាយ ឬក្អក។** តាមពិតផ្លែឈើដូចជាក្រូច និងប៉េងប៉ោះ សំបូរវីតាមីនសេ ដែលអាចជួយប្រយុទ្ធនឹងជំងឺផ្តាសាយ និងការបង្ករោគផ្សេងៗទៀត។

៣. **ជាការមិនពិតទេដែលថា មិនអាចបរិភោគអាហារមួយចំនួន ដូចជាសាច់ជ្រូក គ្រឿងហឹរ ឬត្របែក នៅពេលលេបថ្នាំ។** ទោះជាយ៉ាងណាក៏ដោយ នៅពេលនរណាម្នាក់មានជំងឺក្រពះ ឬជំងឺនៅផ្នែកណាមួយនៃប្រព័ន្ធរំលាយអាហារ ការបរិភោគអាហារដែលមានជាតិខ្លាញ់ ឬប្រេងច្រើន អាចធ្វើឲ្យជំងឺនោះកាន់តែធ្ងន់ធ្ងរ មិនថាគាត់កំពុងលេបថ្នាំឬមិនលេបក៏ដោយ។

# របបអាហារពិសេសសម្រាប់បញ្ហាសុខភាពផ្សេងៗ

## ភាពស្លេកស្លាំង

អ្នកដែលមានភាពស្លេកស្លាំង មានឈាមរាវ។ វាកើតឡើងនៅពេលឈាមត្រូវបានបាត់បង់ ឬបំផ្លាញលឿនជាងការផលិតឡើងវិញរបស់រាងកាយ។ ការបាត់បង់ឈាមដោយការមានរបួសធ្ងន់ ការហូរឈាមដោយសារជំងឺដំបៅក្រពះ ឬជំងឺរាកមួល អាចបណ្តាលឲ្យមានភាពស្លេកស្លាំង។ ជំងឺគ្រុនចាញ់ក៏អាចបណ្តាលឲ្យមានភាពស្លេកស្លាំងដែរ ដោយវាបំផ្លាញគោលិកាឈាមក្រហម។ ការមិនបានបរិភោគអាហារសំបូរជាតិដែកគ្រប់គ្រាន់ ក៏អាចបណ្តាលឲ្យមានភាពស្លេកស្លាំងដែរ ឬធ្វើឲ្យភាពស្លេកស្លាំងកាន់តែធ្ងន់ធ្ងរថែមទៀត។

ស្ត្រីអាចក្លាយជាមានភាពស្លេកស្លាំងដោយសារការបាត់បង់ឈាមនៅពេលមានឈាមរដូវ ឬពេលសម្រាលកូន បើពួកគាត់មិនបានបរិភោគអាហារដែលរាងកាយត្រូវការ។ ស្ត្រីមានផ្ទៃពោះមានការប្រឈមនឹងការមានភាពស្លេកស្លាំងធ្ងន់ធ្ងរ ដោយសារគាត់ត្រូវការផលិតឈាមបន្ថែមសម្រាប់ការលូតលាស់នៃគភ៌របស់គាត់។

ចំពោះកុមារ ភាពស្លេកស្លាំងអាចកើតឡើងដោយសារការមិនបានបរិភោគអាហារសំបូរជាតិដែក។ វាក៏អាចកើតឡើងដោយសារការមិនបានចាប់ផ្តើមផ្តល់អាហារបន្ថែមខ្លះទៅលើទឹកដោះម្តាយ បន្ទាប់ពីទារកមានអាយុលើស៦ខែ។ មូលហេតុជាញឹកញាប់នៃភាពស្លេកស្លាំងធ្ងន់ធ្ងរចំពោះកុមារ គឺការបង្ករោគនៃព្រូនទំពក់ (មើលទំ.១៤២) ជំងឺរាករ៉ាំរ៉ៃ និងជំងឺរាកមួល។

*រោគសញ្ញានៃភាពស្លេកស្លាំងមាន ៖*

- *ស្បែកស្លេកស្លាំង ឬថ្លា*
- *ស្លេកស្លាំងនៅផ្នែកខាងក្នុងនៃត្របកភ្នែក*
- *ក្រចកដែស*
- *អញ្ចាញធ្មេញស្លេកស្លាំង*
- *ខ្សោយហើយអស់កម្លាំង*



- *បើភាពស្លេកស្លាំងនេះធ្ងន់ធ្ងរ មុខនិងជើងអាចហើមបេះដូងដើរញាប់ ហើយអ្នកជំងឺអាចមានដង្ហើមខ្លីៗ។*
- *កុមារនិងស្ត្រីដែលចូលចិត្តបរិភោគរបស់មិនស្អាត ទំនងជាមានបញ្ហាស្លេកស្លាំង។*

*ការព្យាបាល និងការបង្ការភាពស្លេកស្លាំង ៖*

- **បរិភោគអាហារសំបូរជាតិដែក។** សាច់ ត្រី និងមាន់ មានជាតិដែកខ្ពស់ ជាពិសេសគឺថ្លើម។ បន្លែពណ៌បៃតងចាស់ សណ្តែក ក៏មានជាតិដែកដែរ។ ការចម្អិនអាហារក្នុងឆ្នាំងដែក ក៏មានប្រយោជន៍ផងដែរ (មើលទំ.១១៧)។ ដើម្បីជួយឲ្យរាងកាយស្រូបយកជាតិដែកបន្ថែម បរិភោគបន្លែស្រស់ និងផ្លែឈើនៅពេលបាយ ហើយចៀសវាងផឹកកាហ្វេនិងតែជាមួយអាហារ។
- បើភាពស្លេកស្លាំងមានសភាពមធ្យមឬធ្ងន់ធ្ងរ អ្នកនោះគួរលេបថ្នាំជាតិដែក (ថ្នាំគ្រាប់ហ្វែរ ស៊ុលហ្វាត ទំ.៣៩៣)។ នេះសំខាន់ណាស់សម្រាប់ស្ត្រីមានផ្ទៃពោះដែលមានភាពស្លេកស្លាំង។ ចំពោះស្ទើរតែគ្រប់ករណីទាំងអស់នៃភាពស្លេកស្លាំង ថ្នាំគ្រាប់ហ្វែរស៊ុលហ្វាត មានប្រសិទ្ធភាពជាងសារធាតុចម្រាញ់ពីថ្លើម ឬវីតាមីនបេ១២។ តាមក្បួនទូទៅ **ជាតិដែកគួរត្រូវបានលេបតាមមាត់ មិនមែនដោយការចាក់ទេ** ព្រោះការចាក់បញ្ចូលជាតិដែក អាចមានគ្រោះថ្នាក់ ហើយវាក៏មិនមានប្រសិទ្ធភាពជាងថ្នាំលេបដែរ។
- បើភាពស្លេកស្លាំងបណ្តាលមកពីជំងឺរាកមួល (រាកមានឈាម) ព្រូនទំពក់ ជំងឺគ្រុនចាញ់ ឬជំងឺដទៃទៀត នោះក៏ត្រូវទទួលការព្យាបាលផងដែរ។
- បើភាពស្លេកស្លាំងមានសភាពធ្ងន់ធ្ងរ ឬគ្មានការធូរស្រាល នោះត្រូវរកជំនួយពីគ្រូពេទ្យ។ បញ្ហានេះសំខាន់ណាស់ចំពោះស្ត្រីមានផ្ទៃពោះ។

**មានស្ត្រីជាច្រើនមានភាពស្លេកស្លាំង។** ស្ត្រីដែលមានភាពស្លេកស្លាំងមានការប្រឈមខ្ពស់នឹងការរលូតកូន និងការហូរឈាមដ៏គ្រោះថ្នាក់ ក្នុងពេលសម្រាលកូន។ **វាជាការសំខាន់ណាស់ដែលស្ត្រីទាំងឡាយត្រូវបរិភោគអាហារសំបូរជាតិដែក ឲ្យបានច្រើនតាមដែលអាចធ្វើបាន** ជាពិសេសក្នុងពេលមានផ្ទៃពោះ។ ការពន្យារពេល២ទៅ៣ឆ្នាំមុននឹងមានផ្ទៃពោះម្តងទៀត ធ្វើឲ្យស្ត្រីអាចមានកម្លាំង និងផលិតឈាមថ្មីឡើងវិញ (មើលជំពូក២០)។

# ជំងឺក្រិស



ពន្លឺព្រះអាទិត្យគឺជាថ្នាំការពារ និងព្យាបាលជំងឺក្រិស ដ៏ប្រសើរបំផុត។

កុមារដែលស្បែករបស់វាមិនដែលត្រូវពន្លឺព្រះអាទិត្យ អាចក្លាយជាមានជើងកោង និងអាចមានការខូចទ្រង់ទ្រាយឆ្អឹងផ្សេងៗទៀត (ជំងឺក្រិស)។ គេអាច ទប់ទល់នឹងជំងឺនេះបាន ដោយឲ្យកុមារផឹកទឹកដោះប៉ូវកម្លាំង និងវីតាមីនដេ(មាននៅក្នុងប្រេងថ្លើមត្រី)។ ទោះជាយ៉ាងនេះក្តី **ការបង្ការដែលងាយស្រួល និងចំណាយប្រាក់តិចនោះ គឺដាក់ស្បែករបស់កុមារ ឲ្យប៉ះនឹងពន្លឺព្រះអាទិត្យដោយផ្ទាល់** រយៈពេលយ៉ាងតិច១០នាទីក្នុង១ថ្ងៃ ឬក៏យូរជាងនេះ ជាញឹកញាប់។ (ប៉ុន្តែត្រូវប្រយ័ត្ន កុំឲ្យរលាកស្បែករបស់កុមារ)។ មិនត្រូវឲ្យថ្នាំវីតាមីនដេក្នុងកម្រិតខ្ពស់ និងក្នុងរយៈពេលយូរទេ ព្រោះវាអាចធ្វើឲ្យកុមារពុលបាន។

# ជំងឺលើសឈាម

ជំងឺលើសឈាមអាចបណ្តាលឲ្យមានបញ្ហាជាច្រើន ដូចជាជំងឺបេះដូង ជំងឺតម្រងនោម និងជំងឺដាច់សរសៃឈាមខួរក្បាល។ មនុស្សធាត់ទំនងជាងាយមានជំងឺលើសឈាម។


ឧបករណ៍វាស់សម្ពាធឈាម

រោគសញ្ញានៃជំងឺលើសឈាមដ៏គ្រោះថ្នាក់ ៖

- ឈឺក្បាលញឹកញាប់
- បេះដូងលោតខ្លាំងហើយមានដង្ហើមខ្លីៗពេលធ្វើការងារបន្តិចបន្តួច
- ខ្សោយ និងវិលមុខ
- ជួនកាលឈឺស្មាខាងឆ្វេង និងទ្រូង

បញ្ហាទាំងនេះអាចបណ្តាលមកពីជំងឺដទៃទៀតដែរ។ ដូច្នេះបើអ្នកណាម្នាក់ សង្ស័យថាខ្លួនមានជំងឺលើសឈាម គាត់គួរទៅជួបបុគ្គលិកសុខាភិបាល ដើម្បីវាស់សម្ពាធឈាម។

*ចំណាំ ៖* ជំងឺលើសឈាមក្នុងដំណាក់កាលដំបូង មិនមានរោគសញ្ញាអ្វីទេ ហើយគេគួរបញ្ចុះវា **មុនពេលមាន**រោគសញ្ញាគ្រោះថ្នាក់កើតឡើង។ អ្នកដែលមានទម្ងន់លើស ឬសង្ស័យថាខ្លួនមានជំងឺលើសឈាម គប្បីទៅពិនិត្យសម្ពាធឈាមឲ្យបានទៀងទាត់។ ចំពោះសេចក្តីណែនាំអំពីការវាស់សម្ពាធឈាម សូមមើលទំ.៤១០ និង៤១១។

ត្រូវធ្វើអ្វីខ្លះដើម្បីបង្ការ ឬថែទាំជំងឺលើសឈាម ៖

- បើលើសទម្ងន់ បញ្ចុះទម្ងន់ (មើលទំព័របន្ទាប់)។
- ជៀសវាងអាហារជាតិខ្លាញ់ ជាពិសេសខ្លាញ់ជ្រូក និងអាហារដែលមានស្ករនិងជាតិម្សៅច្រើន។ ប្រើប្រេងបន្លែជំនួសខ្លាញ់ជ្រូកជានិច្ច។
- រៀបចំនិងបរិភោគអាហារដែលមានជាតិប្រៃបន្តិចបន្តួច ឬគ្មានជាតិប្រៃទាល់តែសោះ។
- មិនត្រូវជក់បារី។ មិនត្រូវផឹកស្រា កាហ្វេ ឬទឹកតែច្រើនទេ។
- នៅពេលដែលសម្ពាធឈាមឡើងខ្ពស់ បុគ្គលិកសុខាភិបាលអាចឲ្យថ្នាំលេបដើម្បីបញ្ចុះសម្ពាធឈាម។ មានមនុស្សជាច្រើនអាចបញ្ចុះសម្ពាធឈាមរបស់ពួកគេបាន ដោយបញ្ចុះទម្ងន់ បើពួកគេធាត់(ទំព័របន្ទាប់) និងដោយរៀនពីរបៀបបន្ធូរអារម្មណ៍។



# មនុស្សធាត់

ការធាត់ពេកមិនមែនមានសុខភាពល្អទេ។ ការមានខ្លាញ់ច្រើនពេក ធ្វើឲ្យមានជំងឺលើសឈាម ជំងឺបេះដូង ជំងឺដាច់សរសៃឈាមខួរក្បាល ជំងឺថង់ទឹកប្រមាត់ ជំងឺទឹកនោមផ្អែម ជំងឺរលាកសន្លាក់ជើង និងបញ្ហាផ្សេងៗទៀត។

មនុស្សធាត់គួរបញ្ចុះទម្ងន់ដោយ ៖

- បរិភោគអាហារដែលមានជាតិខ្លាញ់ឬជាតិប្រេងតិចតួច
- បរិភោគស្ករតិចតួច ឬអាហារដែលមានជាតិផ្អែមតិចតួច
- បង្កើនការធ្វើលំហាត់ប្រាណ
- **មិនត្រូវបរិភោគអាហារច្រើនពេកទេ**
  ជាពិសេសអាហារដែលមានជាតិម្សៅ ដូចជាបាយ ពោត នំប៉័ង ដំឡូង ត្រាវ មីកញ្ចប់។ មនុស្សធាត់មិនគួរបរិភោគ បាយ លើសពីមួយចានរួមជាមួយអាហារផ្សេងៗទៀតឡើយ។ ប៉ុន្តែពួកគេអាចបរិភោគផ្លែឈើ និងបន្លែបន្ថែមបាន។

*ការបង្ការ ៖* នៅពេលអ្នកចាប់ផ្តើមមានទម្ងន់លើស ចាប់ផ្តើមធ្វើតាមការណែនាំខាងលើនេះ។

# ការទល់លាមក

អ្នកដែលមានលាមករឹង និងមិនបានបន្ទោរបង់លាមករយៈពេលបីថ្ងៃឬលើសពីនេះ គេនិយាយថាគាត់មានការទល់លាមក។ ជាញឹកញាប់ ការទល់លាមកបណ្តាលមកពីការមានរបបអាហារមិនល្អ (ជាពិសេស ការមិនបានបរិភោគផ្លែឈើ បន្លែបៃតង ឬអាហារមានជាតិសរសៃធម្មជាតិ ដូចជានំប៉័ង) ឬខ្វះការធ្វើលំហាត់ប្រាណ។

**ផឹកទឹកឲ្យបានច្រើន** ហើយបរិភោគផ្លែឈើ បន្លែ និងអាហារដែលមានជាតិសរសៃធម្មជាតិ បន្ថែមទៀត ដូចជាស្រូវសាលី គិនឲ្យម៉ត់ ការុត ស្ពៃមើម គ្រាប់ធញ្ញជាតិ ល្ពៅ ល្ហុង ដែលទាំងអស់នេះល្អជាងការប្រើថ្នាំបញ្ចុះ។ ការបន្ថែមប្រេងបន្លែបន្តិចបន្តួចទៅក្នុងអាហារជារៀងរាល់ថ្ងៃ ក៏ជួយសម្រួលបានដែរ។ ចំពោះមនុស្សចាស់ អាចត្រូវការការដើរ ឬហាត់ប្រាណឲ្យបានច្រើន ដើម្បីឲ្យមានការបន្ទោរបង់លាមកទៀងទាត់។

ចំពោះមនុស្សដែលគ្មានការបន្ទោរបង់លាមករយៈពេល៤ថ្ងៃឬលើសពីនេះ ប្រសិនបើគាត់មិនមានការចុកសៀតក្នុងពោះទេ គាត់អាចប្រើថ្នាំបញ្ចុះធម្មតា ដូចជាម៉ាញ៉េស៊ី។ **តែមិនត្រូវប្រើថ្នាំបញ្ចុះញឹកញាប់ទេ។**

មិនត្រូវឲ្យថ្នាំបញ្ចុះដល់ទារក ឬកុមារតូចៗទេ។ បើទារកទល់លាមកខ្លាំង ដាក់ប្រេងឆាបន្តិចក្នុងរន្ធគូទរបស់វា។ ឬក្នុងករណីចាំបាច់ លូកម្រាមដៃដែលមានលាបប្រេង ដោយថ្នមៗ ដើម្បីបំបែកនិងបញ្ចេញដុំលាមកដែលរឹងនោះមកក្រៅ។

**មិនត្រូវប្រើថ្នាំបញ្ចុះខ្លាំងៗទេ ពិសេសបើមានការឈឺចាប់ក្នុងពោះ។**

# ជំងឺទឹកនោមផ្អែម

អ្នកដែលមានជំងឺទឹកនោមផ្អែម មានជាតិស្ករយ៉ាងច្រើននៅក្នុងឈាម។ ជំងឺនេះអាចចាប់ផ្តើមកើតលើមនុស្សវ័យក្មេង (ជំងឺទឹកនោមផ្អែមលើមនុស្សក្មេង) ឬមនុស្សវ័យចំណាស់(ជំងឺទឹកនោមផ្អែមលើមនុស្សចាស់)។ តាមធម្មតាជំងឺនេះតែងតែមានសភាពធ្ងន់ធ្ងរលើមនុស្សវ័យក្មេង ហើយពួកគេត្រូវការថ្នាំពិសេស (អាំងស៊ុយលីន)ដើម្បីគ្រប់គ្រងជំងឺនេះ។ ប៉ុន្តែជំងឺនេះច្រើនតែកើតលើមនុស្សអាយុលើសពី៤០ឆ្នាំ ដែលបរិភោគច្រើន ហើយធាត់។

រោគសញ្ញាដំបូងនៃជំងឺទឹកនោមផ្អែម ៖

- ស្រេកទឹកជានិច្ច
- នោមញឹកញាប់ និងមានបរិមាណទឹកនោមច្រើន
- តែងតែអស់កម្លាំង
- តែងតែឃ្លានជានិច្ច
- ស្រកទម្ងន់

ក្រោយមក រោគសញ្ញាធ្ងន់ធ្ងរ ៖

- រមាស់ស្បែក
- ព្រិលភ្នែក ដោយពេល
- បាត់បង់ញាណដឹងនៅដៃ ឬជើង
- មានការបង្ករោគជាញឹកញាប់នៅទ្វារមាស
- មានដំបៅនៅជើង ដែលមិនជាសះស្បើយ
- បាត់បង់ស្មារតី(ក្នុងករណីធ្ងន់ធ្ងរ)

រោគសញ្ញាទាំងអស់នេះក៏អាចបណ្តាលមកពីជំងឺផ្សេងទៀតដែរ។ ដើម្បីបញ្ជាក់ថាមនុស្សម្នាក់មានជំងឺទឹកនោមផ្អែម ត្រូវពិនិត្យទឹកនោមរបស់គាត់ ដើម្បីរកមើលជាតិស្ករនៅក្នុងនោះ។ វិធីមួយក្នុងការពិនិត្យទឹកនោម គឺការលិទ្ធទឹកនោមនោះ។ បើវាមានជាតិផ្អែម ឲ្យមនុស្សពីរនាក់ទៀតលិទ្ធមើលដែរ។ សុំឲ្យពួកគេលិទ្ធមើលទឹកនោមមនុស្សបីនាក់ផ្សេងទៀតផងដែរ។ បើគ្រប់គ្នាយល់ស្របថា ទឹកនោមអ្នកនោះផ្អែមជាងគេ នោះគាត់ប្រហែលជាមានជំងឺទឹកនោមផ្អែមហើយ។

វិធីពិនិត្យម្យ៉ាងទៀតគឺ មានស្រមោចរោមទឹកនោម។

វិធីពិនិត្យទឹកនោមមួយទៀតគឺប្រើក្រដាស់ពិសេសមួយប្រភេទ ដូចជាយ៉ូរីស្ទិក(Uristix)។ បើក្រដាស់ប្រែពណ៌នៅពេលគេជ្រលក់វាទៅក្នុងទឹកនោម នោះបានសេចក្តីថាមានជាតិស្ករនៅក្នុងនោះ។

បើអ្នកនោះជាកុមារ ឬមានវ័យជំទង់ គប្បីឲ្យបុគ្គលិកសុខាភិបាល ឬវេជ្ជបណ្ឌិតដែលមានបទពិសោធន៍ពិនិត្យ។

នៅពេលមនុស្សម្នាក់កើតជំងឺទឹកនោមផ្អែមនៅអាយុលើសពី៤០ឆ្នាំ គេអាចគ្រប់គ្រងវាបានយ៉ាងល្អ ដោយមិនចាំបាច់ប្រើថ្នាំ គឺដោយការបរិភោគឲ្យបានត្រឹមត្រូវ។ **របបអាហាររបស់អ្នកជំងឺទឹកនោមផ្អែម មានសារសំខាន់ណាស់ ហើយត្រូវអនុវត្តន៍តាមដោយប្រុងប្រយ័ត្នពេញមួយជីវិត។**

***របបអាហាររបស់អ្នកជំងឺទឹកនោមផ្អែម ៖*** មនុស្សធាត់ដែលមានជំងឺទឹកនោមផ្អែម ត្រូវបញ្ចុះទម្ងន់រហូតទាល់តែមានទម្ងន់ធម្មតា។ **អ្នកជំងឺទឹកនោមផ្អែមមិនត្រូវបរិភោគស្ករ ឬបង្អែម ឬអាហារដែលមានជាតិផ្អែមទេ។** វាជាការសំខាន់ណាស់ដែលពួកគេត្រូវបរិភោគអាហារសំបូរសរសៃឲ្យបានច្រើន ដូចជានំប៉័ងជាដើម។ ប៉ុន្តែអ្នកជំងឺទឹកនោមផ្អែមក៏គួរបរិភោគអាហារជាតិម្សៅដទៃទៀតខ្លះដែរ ដូចជាសណ្តែក បាយ និងដំឡូង ព្រមទាំងអាហារសំបូរប្រូតេអ៊ីនផង។

ចំពោះអ្នកជំងឺទឹកនោមផ្អែមដែលមានវ័យក្មេង ជួនកាលការផឹកទឹកដើមដំបងយក្ស ក៏អាចជួយបានខ្លះដែរ។ របៀបធ្វើគឺកាត់ដើមដំបងយក្សទៅជាចំណែកតូចៗ រួចកិនវាយកទឹក។ ផឹកទឹកនោះម្តង១កែវកន្លះ មួយថ្ងៃ៣ដង មុនពេលបាយ។

ដើម្បីបង្ការការបង្ករោគផ្សេងៗ និងរបួសលើស្បែក សម្អាតធ្មេញក្រោយពេលបរិភោគ សម្អាតស្បែក ហើយត្រូវពាក់ស្បែកជើងជានិច្ចដើម្បីកុំឲ្យមានរបួស។ ចំពោះការមានដំណើរឈាមរត់មិនល្អនៅជើង(ស្បែកពណ៌ចាស់ ឬស្ពឹក) សម្រាកឲ្យញឹកញាប់ ដោយលើកជើងឲ្យខ្ពស់បន្តិច។ ធ្វើដូចការណែនាំសម្រាប់ជំងឺប៉ោងសរសៃឈាមវ៉ែន(ទំ.១៧៥)ដែរ។

# ការមិនរំលាយអាហារ ការក្រហាយក្នុងទ្រូង និងជំងឺដំបៅក្រពះ

ការមិនរំលាយអាហារ និងការក្រហាយក្នុងទ្រូង ច្រើនបណ្ដាលមកពីការបរិភោគអាហារដែលមានខ្លាញ់ច្រើនពេក ឬការផឹកស្រាឬកាហ្វេច្រើនពេក។ បញ្ហានេះធ្វើឲ្យក្រពះផលិតជាតិអាស៊ីតបន្ថែម ដែលធ្វើឲ្យពិបាកក្នុងខ្លួន ឬមានអារម្មណ៍ក្រហាយនៅក្នុងក្រពះឬត្រង់កណ្ដាលដើមទ្រូង។ អ្នកខ្លះយល់ច្រឡំថាការឈឺទ្រូងបែបនេះ ដែលគេហៅថាការក្រហាយក្នុងទ្រូង ជាជំងឺបេះដូង ជាជាងថាវាជាការមិនរំលាយអាហារ។ បើការឈឺចាប់នេះកាន់តែខ្លាំងឡើងនៅពេលដេក នោះវាប្រហែលជាការក្រហាយក្នុងទ្រូងហើយ។

ការមិនរំលាយអាហារជាញឹកញាប់ឬជាប្រចាំ គឺជារោគសញ្ញានៃជំងឺដំបៅក្រពះ។

**ជំងឺដំបៅក្រពះគឺជាដំបៅរ៉ាំរ៉ៃមួយនៅក្នុងក្រពះ ឬពោះវៀនតូច ដែលបណ្ដាលមកពីមានជាតិអាស៊ីតច្រើនពេក។** វាអាចធ្វើឲ្យមានការឈឺចាប់រ៉ាំរ៉ៃ(ឬជួនកាលឈឺមុត)នៅចុងក្រពះ។ ដូចគ្នានឹងការមិនរំលាយអាហារដែរ ការឈឺចាប់នេះអាចធូរស្រាលនៅពេល បរិភោគអាហារ ឬផឹកទឹកច្រើន។ ការឈឺចាប់នេះតែងតែកើនឡើង បន្ទាប់ពីបរិភោគអាហារបានមួយម៉ោង ឬលើសពីនេះ បើអ្នកជំងឺមិនបានបរិភោគអាហារ ឬបន្ទាប់ពីគាត់ផឹកស្រាឬបរិភោគអាហារ ខ្លាញ់ ឬអាហារហឹរ។ ការឈឺចាប់តែងតែមានសភាពធ្ងន់ធ្ងរនៅពេលយប់។ បើគ្មានការពិនិត្យយ៉ាងពិសេសទេ(ការថតឆ្លុះ) នោះគេមានការពិបាកណាស់ក្នុងការសន្និដ្ឋានថាអ្នកដែលមានការឈឺចាប់នៅក្រពះ មានឬគ្មានជំងឺដំបៅក្រពះនោះទេ។




គឺជាការមានដំបៅនៅក្នុងក្រពះ ឬពោះវៀន។

បើជំងឺដំបៅក្រពះនោះធ្ងន់ធ្ងរ វាអាចបណ្ដាលឲ្យក្អួត ជួនកាលមានលាយឈាមស្រស់ៗផង ឬមានកំណកឈាមដែលមើលទៅដូចជាកាកកាហ្វេ។ លាមកលាយឈាមដែលបណ្ដាលមកពីជំងឺដំបៅក្រពះ តែងតែមានពណ៌ខ្មៅដូចកៅស៊ូថ្នល់។

*ប្រយ័ត្ន ៖* ជំងឺដំបៅក្រពះខ្លះគ្មានការឈឺចាប់ទេ ឬមានសភាពស្ងប់ស្ងាត់ ហើយរោគសញ្ញាដំបូងគឺមាន**ឈាមក្នុងកម្អួត ឬមានលាមកស្អិតហើយខ្មៅ។** នេះគឺបញ្ហាដែលត្រូវការការសង្គ្រោះបន្ទាន់។ អ្នកជំងឺអាចមានការហូរឈាមរហូតដល់ស្លាប់ យ៉ាងរហ័ស។ ត្រូវរកជំនួយពីគ្រូពេទ្យជាបន្ទាន់។

*ការបង្ការ និងការព្យាបាល ៖*

ទោះបីជាការឈឺចាប់នៅក្នុងក្រពះឬនៅក្នុងទ្រូង បណ្ដាលមកពីការក្រហាយនៅក្នុងទ្រូង ការមិនរំលាយអាហារ ឬជំងឺដំបៅក្រពះ ក៏ដោយ ក៏សេចក្ដីណែនាំជាមូលដ្ឋានប៉ុន្មានចំណុចខាងក្រោមនេះ នឹងជួយសម្រាលការឈឺចាប់ និងបង្ការមិនឲ្យវាកើតឡើងទៀតបាន។

- **មិនត្រូវបរិភោគអាហារច្រើនពេកទេ។** បរិភោគតិចៗ ព្រមទាំងឧស្សាហ៍បរិភោគអាហារសម្រន់ខ្លះៗ នៅចន្លោះពេលបាយនីមួយៗ។ បរិភោគអាហារដែលហាក់ដូចជាជួយបន្ថយការឈឺចាប់ និងមិនបណ្ដាលឲ្យមានការឈឺចាប់ទេ។
- **កត់ចំណាំនូវអាហារឬភេសជ្ជៈដែលធ្វើឲ្យមានការឈឺចាប់កាន់តែខ្លាំង រួចជៀសវាងរបស់ទាំងនោះ។** តាមធម្មតារបស់ទាំងនេះរួមមានស្រា កាហ្វេ ម្ទេស ម្រេច ភេសជ្ជៈជាតិកាបូណាត(សូដា កូកាកូឡា) និងអាហារដែលមានជាតិខ្លាញ់។
- បើការក្រហាយក្នុងទ្រូងនេះមានសភាពធ្ងន់ធ្ងរនៅពេលយប់ នៅពេលដេកផ្ទារព្យាយាមដេកដោយឲ្យពាក់កណ្ដាលខ្លួនខាងលើ ឡើងខ្ពស់ខ្ពស់បន្តិច។







- **ផឹកទឹកឲ្យបានច្រើន។** ព្យាយាមផឹកទឹកពីរកែវធំ មុននិងក្រោយពេលបរិភោគអាហារម្តងៗ។ ជាមួយគ្នានេះដែរ ត្រូវផឹកទឹកឲ្យបានច្រើននៅចន្លោះពេលអាហារនីមួយៗ។ បើការឈឺចាប់មានការធូរស្រាលហើយ ក៏ត្រូវផឹកទឹកតាមរបៀបនេះដែរ ទោះបីជានៅពេលដែលគ្មានការឈឺចាប់ក៏ដោយ។
- **កុំជក់បារី។** ការជក់បារីបង្កើនជាតិអាស៊ីតក្នុងក្រពះ ហើយធ្វើឲ្យបញ្ហាកាន់តែធ្ងន់ធ្ងរ។
- **លេបថ្នាំប្រឆាំងជាតិអាស៊ីត។** ថ្នាំប្រឆាំងជាតិអាស៊ីតដែលល្អបំផុតនិងមានសុវត្ថិភាពបំផុត គឺមានជាតិម៉ាញ៉េស្យូម និងអាលុយមីញ៉ូមអ៊ីដ្រុកស៊ីដ។ (មើលទំ.៣៨១ សម្រាប់ព័ត៌មានអំពីកម្រិតប្រើប្រាស់ និងការប្រុងប្រយ័ត្នរបស់ថ្នាំប្រឆាំងជាតិអាស៊ីដផ្សេងៗ)។
- ចំពោះការឈឺចាប់ខ្លាំង ឬជំងឺដំបៅក្រពះដែលគ្មានការធូរស្រាល សាកលេបថ្នាំស៊ីមេទីឌីន(តាហ្គាម៉េត Tagamet ទំ.៣៨២) ឬថ្នាំរ៉ានីទីឌីន(Ranitidine)(ទំ.៣៨២)។ ថ្នាំទាំងនេះមានតម្លៃថ្លៃណាស់ ប៉ុន្តែវាមានប្រសិទ្ធភាពក្នុងការបន្ថយការឈឺចាប់ និងជួយឲ្យដំបៅជាសះ។ ប៉ុន្តែជំងឺដំបៅក្រពះក៏អាចកើតឡើងវិញទៀតបានដែរ។
- **ប្រទាលកន្ទុយក្រពើ** មានដុះនៅក្នុងប្រទេសជាច្រើន ហើយត្រូវបានគេនិយាយថាអាចព្យាបាលជំងឺដំបៅក្រពះបាន។ ទឹករអិលនៅក្នុងដើមរបស់វាអាចបន្ថយការឈឺចាប់ ការរមាស់ និងជួយការពារមិនឲ្យមានដំបៅក្លាយ។ វិធីធ្វើ ៖ ចិតសំបករឹងខាងក្រៅចេញ ហើយកាត់ជាបន្ទះស្តើងៗ រួចយកមកបិតពីលើកន្លែងរលាក ឬដំបៅ។ ម្យ៉ាងទៀត ប្រទាលកន្ទុយក្រពើក៏អាចជួយព្យាបាលជំងឺដំបៅក្រពះ ឬពោះវៀនដែរ។ ចិញ្ច្រាំស្លឹកឲ្យតូចៗ ហើយត្រាំក្នុងទឹកមួយយប់ រួចផឹកម្តងមួយកែវរៀងរាល់ ២ម៉ោងម្តង។ ទឹករបស់វាឡើងខាប់អន្តាយ ហើយល្វីង។



*សូមប្រយ័ត្ន ៖*

១. មានវេជ្ជបណ្ឌិតជាច្រើនបានណែនាំឲ្យផឹកទឹកដោះគោដើម្បីព្យាបាលជំងឺដំបៅក្រពះ។ ប៉ុន្តែ ទោះបីជាទឹកដោះគោអាចបន្ថយការឈឺចាប់ នៅពេលបន្ទាប់ពីផឹករួចភ្លាមៗក៏ដោយ តែវាក៏បណ្តាលឲ្យមានការកើនឡើងនៃជាតិអាស៊ីតក្នុងក្រពះ ដែលអាចធ្វើឲ្យជំងឺដំបៅក្រពះកាន់តែធ្ងន់ធ្ងរថែមទៀត។ សព្វថ្ងៃនេះ វេជ្ជបណ្ឌិតជា ច្រើននិយាយថា **មិនត្រូវផឹកទឹកដោះគោ ដើម្បីព្យាបាលជំងឺដំបៅក្រពះទេ។**

២. ដូចទឹកដោះគោដែរ ថ្នាំប្រឆាំងជាតិអាស៊ីដខ្លះ ដូចជា**សូដ្យូមកាបូណាត** (សូដា) និងអាល់ការស៊ែលច័ហ្ស៊ី (Alka-Seltzer) អាចបន្ថយបញ្ហាមិនរំលាយអាហារបានយ៉ាងរហ័ស ប៉ុន្តែក្រោយមក អាចបណ្តាលឲ្យមានជាតិអាស៊ីដជាច្រើនដែរ។ គួរប្រើវាសម្រាប់តែពេលមានបញ្ហាមិនរំលាយអាហារម្តងម្កាលតែប៉ុណ្ណោះ ហើយមិនត្រូវប្រើសម្រាប់ ជំងឺដំបៅក្រពះទេ។ នេះក៏ដូចគ្នានឹងថ្នាំប្រឆាំងជាតិអាស៊ីដដែលមានជាតិកាល់ស្យូមដែរ។

៣. ថ្នាំពេទ្យខ្លះដូចជាអាស្ពីរីន(Aspirin) និងអំបិលដែក ធ្វើឲ្យជំងឺដំបៅក្រពះកាន់តែធ្ងន់ធ្ងរ។ អ្នកដែលមានរោគសញ្ញានៃជំងឺដំបៅក្រពះ ឬមិនរំលាយអាហារ គួរចៀសវាងថ្នាំទាំងនេះ ឬលេបថ្នាំនេះដោយប្រុងប្រយ័ត្នបំផុត(ជាមួយអាហារ ទឹកយ៉ាងច្រើន និងអាចជាមួយថ្នាំប្រឆាំងជាតិអាស៊ីដ)។ ថ្នាំគ័រទីកូស្តេរ៉ូអ៊ីដ(Cortico steroids) ក៏ធ្វើឲ្យជំងឺដំបៅក្រពះកាន់តែធ្ងន់ធ្ងរ ឬបណ្តាលឲ្យមានដំបៅក្រពះ(មើលទំ.៥១)។

វាជាការសំខាន់ណាស់ដែលត្រូវព្យាបាលជំងឺដំបៅក្រពះឲ្យបានទាន់ពេល។ បើមិនដូច្នេះទេវាអាចនាំឲ្យមានការហូរឈាមយ៉ាងគ្រោះថ្នាក់ ឬការរលាកស្រោមពោះ។ ជាធម្មតាជំងឺដំបៅក្រពះអាចមានភាពធូរស្រាល បើអ្នកជំងឺមានការប្រុងប្រយ័ត្នចំពោះអ្វីដែលពួកគេបរិភោគ និងផឹក។ ការមានកំហឹង ភាពតានតឹង និងការមួម៉ៅក្នុងចិត្ត បង្កើនជាតិអាស៊ីដនៅក្នុងក្រពះ។ ការរៀនបន្ធូរអារម្មណ៍ និងធ្វើចិត្តឲ្យស្ងប់ នឹងអាចជួយបានមួយផ្នែកដែរ។ ការថែទាំបន្តគឺជាការចាំបាច់ក្នុងការបង្ការជំងឺដំបៅក្រពះមិនឲ្យកើតឡើងទៀត។

លើសពីនេះទៅទៀត ត្រូវ**ជៀសវាងបញ្ហាដែលបណ្តាលមកពីជាតិអាស៊ីដក្នុងក្រពះ ដោយការមិនបរិភោគច្រើនពេក ការមិនផឹកស្រា ឬកាហ្វេច្រើនពេក និងការមិនជក់បារី។**

# ជំងឺពកក

ជំងឺពកកគឺជាការរីកធំ ឬការមានដុំធំនៅតំបន់បំពង់ក ដែលបណ្តាលមកពីការលូតលាស់មិនប្រក្រតីនៃក្រពេញទីរ៉ូអ៊ីដ។

ជំងឺពកកភាគច្រើនបណ្តាលមកពីកង្វះជាតិអ៊ីយ៉ូដក្នុងរបបអាហារ។ ម្យ៉ាងទៀត កង្វះជាតិអ៊ីយ៉ូដនៅក្នុងអាហាររបស់ស្ត្រីមានផ្ទៃពោះ ជួនកាលក៏អាចបណ្តាលឲ្យទារកស្លាប់ ឬធ្វើឲ្យទារកដែលសម្រាលមក មានបញ្ហាអប្ប ឬថ្លង់( ជំងឺមិនគ្រប់ទឹក ទំ.៣១៨ )។ ប៉ុន្តែបញ្ហាទាំងនេះក៏អាចកើតឡើងបានដែរ ទោះបីជាម្តាយគ្មានជំងឺពកកក៏ដោយ។

ជំងឺពកកនិងជំងឺមិនគ្រប់ទឹក កើតមានជាញឹកញាប់បំផុតនៅតំបន់ភ្នំ ដែលមានជាតិអ៊ីយ៉ូដធម្មជាតិតិចតួចនៅក្នុងដីក្នុងទឹក ឬក្នុងអាហារ។ នៅតំបន់ទាំងនេះ ការបរិភោគអាហារមួយចំនួនច្រើនពេក ដូចជាដំឡូងមី ធ្វើឲ្យអ្នកនោះមានការប្រឈមខ្ពស់នឹងការកើតជំងឺពកក។

*វិធីបង្ការឬព្យាបាលជំងឺពកក និងបង្ការជំងឺមិនគ្រប់ទឹក ៖*

មនុស្សគ្រប់រូបដែលរស់នៅក្នុងតំបន់ដែលមានអ្នកកើតជំងឺពកក គួរប្រើប្រាស់**អំបិលដែលមានជាតិអ៊ីយ៉ូដ**។ ការប្រើអំបិលដែលមានជាតិអ៊ីយ៉ូដជួយបង្ការប្រភេទជំងឺពកកដែលកើតមានជាញឹកញាប់ និងជួយព្យាបាលជំងឺពកក។ ( ដុំពកដែលយូរ និងរឹង អាចយកចេញបានដោយការវះកាត់តែម្យ៉ាងប៉ុណ្ណោះ ប៉ុន្តែជាទូទៅ វាមិនចាំបាច់ទេ។)

បើមិនអាចរកអំបិលដែលមានជាតិអ៊ីយ៉ូដបានទេ ប្រើតាំងទៀអ៊ីយ៉ូដ។ បន្តក់ថ្នាំនេះមួយដំណក់ក្នុងទឹកមួយកែវ ហើយផឹកជារៀងរាល់ថ្ងៃ។ សូមប្រយ័ត្ន ៖ ការប្រើតាំងទៀអ៊ីយ៉ូដនេះច្រើនពេក ធ្វើឲ្យពុលបាន។ ការប្រើលើសពីមួយដំណក់ក្នុងមួយថ្ងៃ អាចបណ្តាលឲ្យជំងឺពកកកាន់តែធ្ងន់ធ្ងរ។ ទុកដាក់ដបថ្នាំនេះនៅកន្លែងដែលក្មេងមិនអាចយកបាន។ ការប្រើអំបិលដែលមានជាតិអ៊ីយ៉ូដមានសុវត្ថិភាពជាង។

ការព្យាបាលជំងឺពកកតាមបែបបុរាណភាគច្រើនពុំមានប្រសិទ្ធភាពទេ។ ប៉ុន្តែ ការបរិភោគក្តាម និងអាហារសមុទ្រផ្សេងៗ អាចជួយបានខ្លះដែរ ព្រោះវាមានជាតិអ៊ីយ៉ូដ។ ការបន្ថែរុក្ខជាតិសមុទ្របន្តិចបន្តួចជាមួយអាហារ ក៏ជួយបន្ថែមជាតិអ៊ីយ៉ូដដែរ។ ប៉ុន្តែ វិធីដែលងាយបំផុតគឺការប្រើអំបិលដែលមានជាតិអ៊ីយ៉ូដ។

*វិធីចៀសវាងការកើតជំងឺពកក*

*មិនត្រូវប្រើអំបិលធម្មតាទេ* — *ត្រូវប្រើអំបិលដែលមានជាតិអ៊ីយ៉ូដជានិច្ច*




ម្យ៉ាងទៀត បើអ្នករស់នៅក្នុងតំបន់ដែលសំបូរមនុស្សកើតជំងឺពកក ឬអ្នកចាប់ផ្តើមមានជំងឺពកក ចៀសវាងបរិភោគដំឡូងមី ឬស្ពៃក្តោបច្រើន។

**ចំណាំ ៖** បើអ្នកមានជំងឺពកកមានសភាពញ័រខ្លាំង មានអារម្មណ៍ជ្រួលច្របល់ក្នុងចិត្ត និងមានការលៀនគ្រាប់ភ្នែកមកក្រៅ នោះគាត់ប្រហែលជាមានជំងឺពកកប្រភេទផ្សេងទៀត( toxic goiter )។ សូមទៅពិគ្រោះយោបល់ជាមួយគ្រូពេទ្យ។